ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៤ លេខ ១ ខែមីនា ឆ្នាំ២០២០ តម្លៃ ១.៥០០៛

30th ANNIVERSARY CDRI 1990 - 2020

# ឥទ្ធិពលធនធានសាលារៀន លើលទ្ធផលសិក្សារបស់សិស្ស ក្នុងប្រទេសកម្ពុជា៖ ភស្តុតាងពីកម្មវិធីអន្តរជាតិ ស្ដីពីរង្វាស់តម្លៃលទ្ធផលសិក្សារបស់សិស្ស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍

## សេចក្ដីផ្ដើម

ចំណាយវិស័យអប់រំ មានចំណែកយ៉ាងធំក្នុងចំណាយរបស់រដ្ឋាភិបាលទាំងឡាយ ក្នុងពិភពលោក។ នៅឆ្នាំ២០១៦ ចំណាយអប់រំសកលជាមធ្យម មានទំហំប្រមាណជា ១៥% នៃចំណាយសរុបរបស់រដ្ឋាភិបាលនានា ហើយដោយឡែក រដ្ឋាភិបាលកម្ពុជាបានបែងចែកចំណាយថវិកាចរន្តសរុប ប្រមាណជា ១៥% ទៅ ២០% សម្រាប់វិស័យអប់រំ (UNESCO 2017; World Bank 2020)។ សំណួរមួយដែលរួមទាំងអ្នកស្រាវជ្រាវ និងអ្នកកសាងគោលនយោបាយចង់ដឹងចម្លើយ គឺថា តើអន្តរាគន៍ក្នុងវិស័យអប់រំ ឬការធ្វើវិនិយោគលើធនធានសាលារៀន (ឧទាហរណ៍ និយាមថ្នាក់ កម្រិតអប់រំរបស់គ្រូ ការផ្ដល់សៀវភៅសិក្សា និង សម្ភារបរិក្ខារសាលាផ្សេងៗ) មានប្រសិទ្ធភាពបែបណា។ ប៉ុន្តែវាហាក់ដូចជាពុំមានចម្លើយណាច្បាស់លាស់សោះ លើសំណួរនេះ ឬក៏មានកម្មវិធីអន្តរាគមន៍ណាមួយ ដែលអាចប្រើបានក្នុងគ្រប់ករណី ព្រោះការសិក្សាមុនៗកន្លងមកស្ដីពី ឥទ្ធិពលរបស់ធនធានសាលាលើការសិក្សារបស់សិស្ស មិនអាចផ្ដល់ការសន្និដ្ឋានច្បាស់ប្រាកដដោយសារមានលទ្ធផលខុសៗគ្នា (Glewwe et al. 2011; Filmer and Pritchett 1999; Checchi 2005)។ ដោយមូលហេតុនេះ វានៅតែមានការខ្វែងមតិគ្នាជាច្រើនថា តើធនធានសាលាបែបណាដែលមានប្រសិទ្ធភាព អាចជួយលើកកម្ពស់ការរៀនសូត្ររបស់សិស្សបាន។

ដូចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀតដែរ សិស្សមួយភាគធំនៅកម្ពុជា ពុំបានទទួលចំណេះដឹងដែលខ្លួនត្រូវរៀនឲ្យបានចេះចាំនៅក្នុងសាលារៀននោះទេ។ លទ្ធផលចេញពីការ



ការសិក្សាខ្លះបានបង្ហាញថា សិស្សក្នុងថ្នាក់មានចំនួនតិចនាក់ គឺសមស្របសម្រាប់ការរៀនសូត្ររបស់សិស្ស ខែមករា ឆ្នាំ២០២០

វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិនៅកម្ពុជា ដែលធ្វើឡើងនៅឆ្នាំ២០១៣ បង្ហាញថា សិស្សប្រមាណ ៥០% ពុំមានចំណេះដឹងជាមូលដ្ឋានក្នុងភាសាខ្មែរ និងគណិតវិទ្យានោះទេ (MoEYS 2015)។ ជាងនេះទៀត នៅពេលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាថ្មី បានធ្វើកំណែទម្រង់ការប្រឡងថ្នាក់ជាតិ ថ្នាក់ទី១២ នៅឆ្នាំ២០១៤ ក្នុងគោលបំណងលុបបំបាត់ការលួចចម្លងផ្សេងៗក្នុងពេលប្រឡង អត្រាប្រឡងជាប់បានថយចុះពីប្រមាណ ៨០% មកត្រឹម ៤៣% (Chhinh 2016)។ ដើម្បីដោះស្រាយបញ្ហា

## មាតិកា

ឥទ្ធិពលធនធានសាលា លើលទ្ធផលសិក្សារបស់សិស្សក្នុងប្រទេសកម្ពុជា ........................................ ១
ការស្វែងយល់ពីចំណេះដឹង និងការចូលរួមសកម្មភាពផ្នែកនយោបាយ របស់យុវជន ........................................ ៧
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ........................ ១៤
– ស្ថានភាពក្នុងប្រទេស........................ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................................ ២៤

អត្ថបទនេះរៀបរៀងដោយ ជា ផល អ្នកស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថាន CDRI និង Ogawa Keiichi សាស្ត្រាចារ្យ នៃ Graduate School of International Cooperation Studies, Kobe University។ សូមយោងអត្ថបទនេះថា៖ Chea Phal and Ogawa Keiichi. 2020. “Effects of School Resources on Student Learning Achievement in Cambodia: Evidence from PISA-D” *Cambodia Development Review* 24 (1): 1–6។

ទាំងនេះ កំណែទម្រង់វិស័យអប់រំនៅកម្ពុជាបានបង្វែរការយកចិត្តទុកដាក់ពីលទ្ធភាពទទួលបានការអប់រំ មកផ្តោតលើគុណភាពអប់រំវិញ។ កំណែទម្រង់ទាំងនោះ មានជាអាទិ៍ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ការលើកកម្ពស់អធិការកិច្ចដើម្បីធានាគុណភាពអប់រំ និងការពង្រឹងរង្វាស់តម្លៃសិក្សារបស់សិស្ស (MoEYS 2019b)។

ទោះមានបញ្ហាដូចខាងលើក្តី ការសិក្សាស្តីពីឥទ្ធិពលធនធានសាលារៀនលើការសិក្សារបស់សិស្សនៅកម្ពុជា នៅមានកម្រិតទាប។ មានការសិក្សាមួយចំនួនតូច ដែលពិនិត្យលើបញ្ហានេះនៅកម្ពុជា (Song 2012; Marshall and Fukao 2019) ប៉ុន្តែការសិក្សាទាំងនោះផ្អែកលើសំណាកទម្រង់ទ្រាយតូច ឬមិនតំណាងឲ្យប្រទេសទាំងមូលនោះទេ។ ការសិក្សានេះព្យាយាមពិនិត្យអង្កេតពី ទំនាក់ទំនងរវាងធនធានសាលាផ្សេងៗជាច្រើនជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស ដោយប្រើទិន្នន័យទ្រង់ទ្រាយធំ ដែលបានមកពី កម្មវិធីអន្តរជាតិស្តីពីរង្វាស់តម្លៃលទ្ធផលសិក្សារបស់សិស្ស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (PISA-D) ដែលកម្ពុជាបានចូលរួមជាលើកទី១ នៅឆ្នាំ២០១៧។

## ការពិនិត្យលើការសិក្សាកន្លងមក

ការសិក្សាមុនៗ ស្តីពីធនធានរបស់សាលារៀនផ្សេងៗជាច្រើនដែលមានទំនាក់ទំនងជាមួយនឹង លទ្ធផលសិក្សារបស់សិស្ស បានផ្តល់ព័ត៌មាន ស្តីពីកត្តាដែលជាធម្មតាត្រូវបានយកមកពិនិត្យ ដូចជា និយាមថ្នាក់ ហេដ្ឋារចនាសម្ព័ន្ធសាលារៀន អាហារនៅសាលារៀន សៀវភៅសិក្សារបស់សិស្ស ផលធៀបគ្រូសិស្ស បទពិសោធន៍គ្រូបង្រៀន និងកម្រិតអប់រំរបស់គ្រូ ជាដើម (Greenwald, Hedges, and Laine 1996; Glewwe et al. 2011)។ ការសិក្សាមួយដែលត្រូវបានទទួលស្គាល់ថាមានឥទ្ធិពលខ្លាំងជាងគេ ស្តីពី ឥទ្ធិពលធនធានសាលារៀនលើការសិក្សារបស់សិស្ស ធ្វើឡើងដោយ Coleman et al. (1966) បានរកឃើញថា ឥទ្ធិពលធនធានសាលារៀនលើការសិក្សារបស់សិស្សមានលក្ខណៈវិជ្ជមាន ប៉ុន្តែមានកម្រិតខ្សោយជាងការរំពឹងទុក រីឯកត្តាគ្រួសាររបស់សិស្សវិញ ហាក់មានឥទ្ធិពលខ្លាំងជាងច្រើន ក្នុងការកំណត់លទ្ធផលសិក្សារបស់សិស្ស។

ជាង ៦០ឆ្នាំ ក្រោយពីរបាយការណ៍ Coleman ត្រូវបានបោះពុម្ពផ្សាយ ការជជែកវែកញែក ស្តីពីឥទ្ធិពលធនធានសាលារៀនលើការសិក្សារបស់សិស្ស នៅតែមានជាបន្តបន្ទាប់ ដោយសារការសិក្សាក្រោយៗមកទៀត បានផ្តល់លទ្ធផលមិនស៊ីគ្នាសោះ (Chowa et al. 2015; Case and Deaton 1999; Fuchs and Wößmann 2008)។ ឧទាហរណ៍ គេយល់ថា និយាមថ្នាក់តូច (ចំនួនសិស្សតិចក្នុងថ្នាក់រៀន) វាប្រសើរជាងនិយាមថ្នាក់ធំ សម្រាប់ការរៀនសូត្ររបស់សិស្ស ប៉ុន្តែការសិក្សាជាក់ស្តែងស្តីពី ឥទ្ធិពលនៃនិយាមថ្នាក់ លើការសិក្សារបស់សិស្ស បានផ្តល់លទ្ធផលមិនដូចគ្នានោះទេ។ ការសិក្សាក្នុង ១១ប្រទេស ដោយប្រើទិន្នន័យបានពី ការវាយតម្លៃអន្តរជាតិស្តីពី និន្នាការក្នុងការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រ (TIMSS) បានរកឃើញថា និយាមថ្នាក់រៀនមានឥទ្ធិពល លើការសិក្សារបស់សិស្ស តែនៅក្នុងប្រទេសខ្លះ ដែលគ្រូបង្រៀនមានប្រាក់ខែមិនគ្រប់គ្រាន់ប៉ុណ្ណោះ (Wößmann and West 2006)។ ការសិក្សាមួយទៀតរបស់ Angrist and Lavy (1999) នៅប្រទេសអ៊ីស្រាអែល បានរកឃើញថា និយាមថ្នាក់តូចមានឥទ្ធិពលវិជ្ជមានលើការសិក្សារបស់សិស្សថ្នាក់ទី៤ និងទី៥ ប៉ុន្តែមិនមានឥទ្ធិពលអ្វីក្នុងចំណោមសិស្សថ្នាក់ទី៣ នោះទេ។ ម្យ៉ាងទៀត ហេដ្ឋារចនាសម្ព័ន្ធសាលារៀនហាក់ដូចមានទំនាក់ទំនងខ្លាំង ជាមួយនឹងលទ្ធផលសិក្សារបស់សិស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែមានឥទ្ធិពលតិចតួច ឬគ្មានឥទ្ធិពលអ្វីសោះ នៅក្នុងប្រទេសអភិវឌ្ឍន៍ (Glewwe et al., 2011)។

## វិធីសាស្ត្រ

ការសិក្សានេះ បានផ្អែកទៅតាម អនុគមន៍ផលិតកម្មអប់រំ (Education Production Function) ដែលគេប្រើជាទូទៅក្នុងការសិក្សាស្តីពី ឥទ្ធិពលនៃធាតុចូលផ្នែកអប់រំទៅលើ លទ្ធផលសិក្សារបស់សិស្ស។ នៅក្នុងអនុគមន៍ផលិតកម្មអប់រំ លទ្ធផលសិក្សារបស់សិស្ស ត្រូវបានកំណត់ដោយធាតុចូលសាលារៀន និងគ្រួសារ ក៏ដូចជា លក្ខណៈសម្បត្តិរបស់សិស្ស រួមទាំងសមត្ថភាពពីកំណើតរបស់សិស្សផងដែរ (Hanushek 1979; Glewwe and Lambert 2010)។

ការសិក្សានេះផ្តោតជាសំខាន់លើ ឥទ្ធិពលនៃកត្តាសាលារៀន និងគ្រូបង្រៀន ទៅលើលទ្ធផលសិក្សារបស់សិស្ស ប៉ុន្តែយើងក៏មានបន្ថែម កត្តាគ្រួសារ (ការអប់រំរបស់ម្តាយ ការអប់រំរបស់ឪពុក និងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់គ្រួសារ) និង កត្តាសិស្ស (យេនឌ័រ កម្រិតថ្នាក់រៀន ការត្រួតថ្នាក់ អវត្តមាន និងការងាររបស់កុមារ) នៅក្នុងម៉ូដែលរបស់យើងដែរ។ សមត្ថភាពពីកំណើតរបស់សិស្ស មិនបានដាក់ចូលក្នុងម៉ូដែលនៃការសិក្សានេះទេ ពីព្រោះនៅក្នុងទិន្នន័យរបស់យើង ពុំមានអថេរសមស្របណាមួយដែលយើងអាចយកមកប្រើជា រង្វាស់សមត្ថភាពពីកំណើតនោះទេ។ យោងតាមការណែនាំរបស់ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍(OECD) ការសិក្សានេះប្រើ ម៉ូដែល HLM (Hierarchical Linear Models) ក្នុងការគណនា ឥទ្ធិពលធនធានសាលារៀន លើការសិក្សារបស់សិស្ស។

ទិន្នន័យក្នុងការសិក្សានេះ បានមកពីកម្មវិធីអន្តរជាតិស្តីពី រង្វាស់តម្លៃលទ្ធផលសិក្សារបស់សិស្ស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (PISA-D) ដែលជាតេស្តស្តង់ដាអន្តរជាតិ លើកទី១ ធ្វើឡើងនៅកម្ពុជា។ សំណាកគំរូ ត្រូវបានជ្រើសរើសចេញពីសិស្សអាយុ ១៥ឆ្នាំ រៀននៅថ្នាក់ទី៧ ឬខ្ពស់ជាង ចំនួន ៥.១៦២នាក់ មកពីសាលារៀនចំនួន ១៧០ (OECD 2018; MoEYS 2018)។ តេស្តដែលមានរយៈពេលពីរម៉ោង លើវិញ្ញាសា អំណាន គណិតវិទ្យា និង វិទ្យាសាស្ត្រ ត្រូវបានរៀបចំ នៅតាមសាលារៀនសំណាកគំរូ នៅចុងឆ្នាំ២០១៧។ ក្រោយពីជម្រុះចោលសំណាក ដែលមិនមានព័ត៌មានគ្រប់គ្រាន់ ឬសមស្រប យើងនៅសល់សំណាកគំរូសិស្ស ចំនួន ៣.១៨៤នាក់ មកពី សាលារៀន ចំនួន ១២១ សម្រាប់ការវិភាគ នៅក្នុងការសិក្សានេះ។ ក្នុងការសិក្សានេះ យើងយកពិន្ទុតេស្ត អំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ធ្វើជារង្វាស់លទ្ធផល

តារាង១៖ និយមន័យអថេរ និងស្ថិតិសង្ខេប

| អថេរ | និយមន័យ | មធ្យម | គម្លាតស្តង់ដា | អប្បបរមា | អតិបរមា |
|---|---|---|---|---|---|
| **លទ្ធផលសិក្សារបស់សិស្ស** | | | | | |
| ពិន្ទុអំណាន | មធ្យមភាគពិន្ទុអំណាន | 331.79 | 53.04 | 142.55 | 520.41 |
| ពិន្ទុគណិតវិទ្យា | មធ្យមភាគពិន្ទុគណិតវិទ្យា | 338.92 | 64.51 | 102.49 | 569.20 |
| ពិន្ទុវិទ្យាសាស្ត្រ | មធ្យមភាគពិន្ទុវិទ្យាសាស្ត្រ | 339.19 | 41.35 | 144.09 | 508.36 |
| **ធនធានសាលារៀន** | | | | | |
| សាលានៅទីក្រុង | អថេរជំនួសមានតម្លៃ ១ បើសិនសាលារៀនស្ថិតក្នុងតំបន់ទីក្រុង ក្រៅពីនោះតម្លៃ ០ | 0.80 | 0.40 | 0.00 | 1.00 |
| សាលារដ្ឋ | អថេរជំនួសមានតម្លៃ ១ បើសិនសាលារៀនជារបស់រដ្ឋ ក្រៅពីនោះតម្លៃ ០ | 0.91 | 0.29 | 0.00 | 1.00 |
| និយាមថ្នាក់ | ចំនួនសិស្សជាមធ្យមក្នុងមួយថ្នាក់ | 44.40 | 12.67 | 13.00 | 53.00 |
| ហេដ្ឋារចនាសម្ព័ន្ធសាលារៀន | សន្ទស្សន៍បង្កើតឡើងដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារមូលដ្ឋាន និងភាពទំនើប របស់សាលារៀន | 4.19 | 0.99 | 2.86 | 10.00 |
| សៀវភៅសិក្សា | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សម្នាក់ៗមានសៀវភៅសិក្សា ក្រៅពីនោះតម្លៃ ០ | 0.52 | 0.50 | 0.00 | 1.00 |
| បង្រៀនតាមសមត្ថភាពសិស្ស | អថេរជំនួសមានតម្លៃ ១ បើសិនសាលារៀនមានរៀបចំការបង្រៀនផ្អែកតាមសមត្ថភាពសិស្ស ក្រៅពីនោះតម្លៃ ០ | 0.37 | 0.48 | 0.00 | 1.00 |
| ថ្នាក់បំប៉ន | អថេរជំនួសមានតម្លៃ ១ បើសិនសាលារៀនផ្តល់ថ្នាក់បំប៉នបន្ថែមដល់សិស្សរៀនយឺត ក្រៅពីនោះតម្លៃ ០ | 0.62 | 0.49 | 0.00 | 1.00 |
| បទពិសោធន៍បង្រៀន | បទពិសោធន៍បង្រៀនជាមធ្យមរបស់គ្រូ | 14.73 | 4.75 | 4.83 | 28.57 |
| គ្រូមានបរិញ្ញាប័ត្រ | ភាគរយគ្រូមានបរិញ្ញាប័ត្រ | 0.61 | 0.22 | 0.00 | 1.00 |
| គ្រូមានបង្រៀនគួរក្រៅម៉ោង | ភាគរយគ្រូមានបង្រៀនគួរក្រៅម៉ោង | 0.60 | 0.19 | 0.00 | 0.92 |
| គ្រូមានការងារទី២ | ភាគរយគ្រូមានការងារទី២ | 0.35 | 0.18 | 0.00 | 1.00 |
| **លក្ខណៈសម្បត្តិរបស់សិស្ស និងគ្រួសារ** | | | | | |
| ភេទស្រី | អថេរជំនួសមានតម្លៃ ១ បើសិនជាសិស្សស្រី ក្រៅពីនោះតម្លៃ ០ | 0.54 | 0.50 | 0.00 | 1.00 |
| កម្រិតថ្នាក់រៀន | កម្រិតថ្នាក់ដែលសិស្សកំពុងរៀននៅពេលធ្វើអង្កេត | 9.75 | 1.11 | 7.00 | 12.00 |
| ត្រួតថ្នាក់ | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សត្រួតថ្នាក់មួយឆ្នាំឬច្រើនឆ្នាំ ក្រៅពីនោះតម្លៃ ០ | 0.28 | 0.45 | 0.00 | 1.00 |
| អវត្តមានរយៈពេលយូរ | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សអវត្តមានលើសពី៣ខែ ក្រៅពីនោះតម្លៃ ០ | 0.07 | 0.25 | 0.00 | 1.00 |
| ការងារមានប្រាក់ឈ្នួល | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សមានធ្វើការងារមានប្រាក់ឈ្នួល ក្រៅពីនោះតម្លៃ ០ | 0.19 | 0.39 | 0.00 | 1.00 |
| ការងាររបស់គ្រួសារ | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សមានធ្វើការងាររបស់គ្រួសារ ក្រៅពីនោះតម្លៃ ០ | 0.43 | 0.49 | 0.00 | 1.00 |
| ម្តាយចេះអក្សរ | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សមានម្តាយចេះអក្សរ ក្រៅពីនោះតម្លៃ ០ | 0.62 | 0.49 | 0.00 | 1.00 |
| ឪពុកចេះអក្សរ | អថេរជំនួសមានតម្លៃ ១ បើសិនសិស្សមានឪពុកចេះអក្សរ ក្រៅពីនោះតម្លៃ ០ | 0.78 | 0.42 | 0.00 | 1.00 |
| ធនធានគ្រួសារ | សន្ទស្សន៍បង្កើតឡើងដោយផ្អែកលើទ្រព្យសម្បត្តិរបស់គ្រួសារ (ឧ. បន្ទប់ទឹករួមគ្នា សៀវភៅក្នុងផ្ទះ ទូរទស្សន៍ ម៉ាស៊ីនបោកខោអាវ កុំព្យូទ័រ រថយន្ត ជាដើម) | 5.25 | 0.84 | 2.60 | 8.93 |

ប្រភព៖ រៀបរៀងដោយអ្នកនិពន្ធ ដោយផ្អែកលើទិន្នន័យ PISA-D Cambodia (2018)

សិក្សារបស់សិស្ស។ តារាង១ បរិយាយនិយមន័យ និងស្ថិតិសង្ខេបរបស់អថេរទាំងឡាយដែលមានប្រើក្នុងការសិក្សានេះ។

## លទ្ធផល

ការសិក្សានេះបានរកឃើញថា កត្តាកំណត់លទ្ធផលសិក្សារបស់សិស្សគួរឲ្យកត់សម្គាល់ រួមមាន ប្រភេទសាលារៀន ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងទីតាំងសាលារៀន។ ទោះបីក្រោយពីបានបញ្ចូលកត្តាទាក់ទងនឹងលក្ខណៈសម្បត្តិរបស់សិស្ស និងគ្រួសារក្តី ក៏សិស្សរៀននៅតាមសាលាឯកជន មានពិន្ទុខ្ពស់ជាងសិស្សរៀននៅសាលារដ្ឋ ១៦ពិន្ទុផ្នែកអំណាន ១៩ពិន្ទុផ្នែកគណិតវិទ្យា និង ១២ពិន្ទុផ្នែកវិទ្យាសាស្ត្រ។ ម៉្យាងទៀត កំណើន ១ឯកតា នៃសន្ទស្សន៍ហេដ្ឋារចនាសម្ព័ន្ធសាលារៀន នាំឲ្យមានកំណើន ៦ពិន្ទុផ្នែកអំណាន ៥ពិន្ទុផ្នែកគណិតវិទ្យា និង ៣ពិន្ទុផ្នែកវិទ្យាសាស្ត្រ។ ការសិក្សានេះក៏បានបង្ហាញពីទំនាក់ទំនងវិជ្ជមាន រវាងសាលារៀននៅទីក្រុងជាមួយនឹងពិន្ទុតេស្តអំណាន និងគណិតវិទ្យាផងដែរ បើទោះបីជាសារៈសំខាន់ផ្នែកស្ថិតិមានកម្រិតខ្សោយបន្តិចក្តី។ យើងឃើញថា ទំនាក់ទំនងវិជ្ជមានរវាងនិយាមថ្នាក់ នឹងលទ្ធផលសិក្សារបស់សិស្ស មានតែនៅក្នុងម៉ូដែលដែលគ្មានកត្តាសិស្ស និងគ្រួសារ ប៉ុណ្ណោះ។ ទំនាក់ទំនងនេះក៏លុបបាត់ទៅវិញ នៅពេលដែលយើងដាក់បញ្ចូលកត្តាសិស្ស និងគ្រួសារ ចូលទៅក្នុងម៉ូដែល។ លទ្ធផលក៏បានបង្ហាញផងដែរថា ការមានសៀវភៅសិក្សាគ្រប់គ្រាន់ និងការរៀបចំបង្រៀនសិស្សតាមសមត្ថភាព ពុំមានទំនាក់ទំនងជាមួយនឹងលទ្ធផលសិក្សារបស់សិស្សនោះទេ។ រីឯទំនាក់ទំនងរវាង ថ្នាក់បំប៉នបន្ថែម នឹងលទ្ធផលសិក្សារបស់សិស្ស វាមានលក្ខណៈមិនច្បាស់លាស់ និងមិនមានសារៈសំខាន់ផ្នែកស្ថិតិ នៅក្នុងម៉ូដែលភាគច្រើន។ មេគុណថ្នាក់បំប៉នបន្ថែម មានសញ្ញាអវិជ្ជមាន និងមានសារៈសំខាន់ផ្នែកស្ថិតិក្នុងកម្រិត ៥% តែនៅក្នុងម៉ូដែលអំណាន និងនៅពេលដែលកត្តាសិស្ស និងគ្រួសារ ត្រូវបានបន្ថែមប៉ុណ្ណោះ។

ចំណែកឯ កត្តាគ្រូបង្រៀនវិញ នៅពេលកត្តាសិស្ស និងគ្រួសារ ត្រូវបានបញ្ចូលក្នុងម៉ូដែល គឺពុំមានកត្តាណាមួយដែលត្រូវបានយកមកពិនិត្យក្នុងការសិក្សានេះ មានទំនាក់ទំនងមានសារៈសំខាន់ផ្នែកស្ថិតិ ជាមួយនឹងលទ្ធផលសិក្សារបស់សិស្សនោះទេ។ នៅក្នុងម៉ូដែលដែលគ្មានកត្តាសិស្ស និងគ្រួសារ យើងឃើញថា បទពិសោធន៍បង្រៀនជាមធ្យមរបស់គ្រូ ភាគរយគ្រូមានបរិញ្ញាប័ត្រ និង ភាគរយគ្រូបង្រៀនគួរក្រៅម៉ោង មានឥទ្ធិពលវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្ស។ ដោយឡែក អត្រាគ្រូមានការងារទី២ មានទំនាក់ទំនងអវិជ្ជមាន ដែលមានសារៈសំខាន់ផ្នែកស្ថិតិក្នុងកម្រិត ១០% ជាមួយនឹងពិន្ទុតេស្តអំណានរបស់សិស្ស នៅក្នុងម៉ូដែលដែលគ្មានកត្តាសិស្ស និងគ្រួសារ។

## សេចក្តីសន្និដ្ឋាន

ឥទ្ធិពលវិជ្ជមាន នៃហេដ្ឋារចនាសម្ព័ន្ធសាលារៀន (ដែលបង្កើតឡើង ដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សាលាជាច្រើន) ទៅលើលទ្ធផលសិក្សារបស់សិស្ស ដែលបានរកឃើញក្នុងការសិក្សានេះ វាមានលក្ខណៈស្របគ្នានឹង ការសិក្សាជាប្រព័ន្ធរបស់ Glewwe et al. (2011) ដែលបានបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើរតួនាទីសំខាន់ក្នុងការរៀនសូត្ររបស់សិស្សនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ ដោយហេតុថា ជាង ៦៥% នៃសាលារៀននៅតាមជនបទប្រទេសកម្ពុជា ពុំមានទាំងបន្ទប់សម្រាប់បណ្ណាល័យផងនោះ (MoEYS 2019a) លទ្ធផលបានពីការសិក្សានេះ ផ្តល់ជាគំនិតថា រដ្ឋាភិបាលគួរវិនិយោគឲ្យបានកាន់តែច្រើនថែមទៀត ទៅលើសាលារៀនជួបការលំបាក ដើម្បីកាត់បន្ថយគម្លាតលទ្ធផលសិក្សារបស់សិស្សនៅតាមតំបន់។ ថ្វីបើក្នុងការសិក្សាជាច្រើនដែល Glewwe et al. (2011) យកមកពិនិត្យ ពួកគេបានរកឃើញថា សៀវភៅសិក្សាមានទំនាក់ទំនងវិជ្ជមានខ្លាំង ជាមួយនឹង ការសិក្សារបស់សិស្សក្តី យើងមិនបានរកឃើញ ភស្តុតាងបញ្ជាក់គាំទ្រចំណុចនេះទេ។ ការរកឃើញក្នុងការសិក្សានេះ មានលក្ខណៈដូចគ្នាទៅនឹងការរកឃើញរបស់ Song (2012) ក្នុងស្រុក ចំនួន ២ នៅកម្ពុជា។ ការស្វែងរកមូលហេតុ ដែលនាំឲ្យសៀវភៅសិក្សាគ្មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការសិក្សារបស់សិស្ស វាស្ថិតនៅក្រៅដែនកំណត់នៃការសិក្សានេះ។ ទោះយ៉ាងនេះក្តី លទ្ធផលរកឃើញនៅខាងលើ អាចជាតម្រុយថា ការប្រើប្រាស់សៀវភៅសិក្សាឲ្យមានប្រសិទ្ធភាព អាចមានសារៈសំខាន់ខ្លាំងជាងការដែលមានសៀវភៅសិក្សាគ្រប់គ្រាន់។ បន្ទាប់ពីបានអនុវត្តគុរុកោសល្យសិស្សមជ្ឈមណ្ឌលជាច្រើនទសវត្សរ៍រួចមក គ្រូបង្រៀននៅកម្ពុជានៅតែបន្តពឹងផ្អែកច្រើនលើការប្រើប្រាស់ក្តារខៀន សម្រាប់ការបង្រៀនក្នុងថ្នាក់ រីឯសិស្សស្តាប់គ្រូយ៉ាងស្ងៀមស្ងាត់ ហើយចម្លងយកអ្វីដែលគ្រូសរសេរនៅលើក្តារខៀន (Song 2015; Tandon and Fukao 2014)។ ឥទ្ធិពលនៃកត្តាគ្រូបង្រៀនផ្សេងៗទៅលើការសិក្សារបស់សិស្ស មានកម្រិតខ្សោយឆ្ងាយជាងការរំពឹងទុក ព្រោះគ្មានកត្តាមួយណា មានសារៈសំខាន់ផ្នែកស្ថិតិនោះទេ នៅពេលដែលកត្តាសិស្ស និងគ្រួសារ ត្រូវបានបន្ថែមក្នុងម៉ូដែល។ ដូច្នេះការសិក្សានាពេលអនាគត គួរធ្វើឲ្យបានស៊ីជម្រៅថែមទៀតស្តីពី កម្សោយនៃទំនាក់ទំនងរវាង លក្ខណៈសម្បត្តិរបស់គ្រូបង្រៀន នឹងការសិក្សារបស់សិស្ស។ គួររំលឹកដែរថា ការសិក្សានេះគ្រាន់តែពិនិត្យលើទំនាក់ទំនងរវាង កត្តាកំណត់នានា នឹងលទ្ធផលសិក្សារបស់សិស្សប៉ុណ្ណោះ ដូច្នេះគួរមានការប្រយ័ត្នប្រយែង ក្នុងការបកស្រាយលទ្ធផលដែលបានរកឃើញ។

## ឯកសារយោង

Angrist, Joshua D, and Victor Lavy. 1999. "Using Maimonides' Rule to Estimate the Effect of Class Size on Scholastic Achievement." The Quarterly Journal of Economics 114 (2): 533–75.

Case, Anne, and Angus Deaton. 1999. "School Inputs and Educational Outcomes in South Africa." The Quarterly Journal of Economics 114 (3): 1047–84.

Checchi, Daniele. 2005. The Economics of Education: Human Capital, Family Background, and Inequlity. Cambridge: Cambridge University Press.

Chhinh, Sitha. 2016. "The Way Forward for Education Reform in Cambodia." In The Political Economy of Schooling in Cambodia, 211–33. New York: Palgrave Macmillan.

Chowa, Gina, Rainier Masa, Yalitza Ramos, and David Ansong. 2015. "How Do Student and School Characteristics Influence Youth Academic Achievement in Ghana? A Hierarchical Linear Modeling of Ghana Youth Save Baseline Data." International Journal of Educational Development 45: 129–40.

Coleman, James S., Earnest Q. Campbel, Carol J. Hobson, and James McPartland. 1966. Equality of Educational Opportunity. Washington, D.C: Government Printing Office.

Filmer, Deon, and Lant Pritchett. 1999. "The Effect of Household Wealth on Educational Attainment: Evidence from 35 Countries." Population and Development Review 25 (1): 85–120.

Fuchs, Thomas, and Ludger Wößmann. 2008. "What Accounts for International Differences in Student Performance? A Re-Examination Using PISA Data." In The Economics of Education and Training, 209–40. Physica-Verlag HD.

Glewwe, Paul, Eric Hanushek, Sarah Humpage, and Renato Ravina. 2011. "School Resources and Educational Outcomes in Developing Countries: A Review of the Literature from 1990 to 2010." 17554. NBER Working Paper Series. Cambridge, MA: NBER

Glewwe, Paul, and Sylvie Lambert. 2010. "Education Production Functions: Evidence from Developing Countries." In International Encyclopedia of Education, 412–22. Elsevier Ltd.

Greenwald, Rob, Larry V. Hedges, and Richard D. Laine. 1996. "The Effect of School Resources on Student Achievement." Review of Educational Research 66 (3): 361–96.

Hanushek, Eric A., 1979. "Conceptual and Empirical Issues in the Estimation of Educational Production." The Journal of Human Resources 14 (3): 351–88.

Marshall, Jeffery H., and Tsuyoshi Fukao. 2019. "Shadow Education and Inequality in Lower Secondary Schooling in Cambodia: Understanding the Dynamics of Private Tutoring Participation and Provision." Comparative Education Review 63 (1): 98–120.

MoEYS. 2015. "Results of Grade Six Student Achievement from the National Assessment in 2013." Phnom Penh: MoEYS.

MoEYS. 2018. "Education in Cambodia: Findings from Cambodia's Experience in PISA for Development." Phnom Penh: MoEYS.

MoEYS. 2019a. "Education Statistics & Indicators 2018-2019." Phnom Penh: MoYES.

MoEYS. 2019b. "Education Strategic Plan 2019-2023." Phnom Penh: MoEYS.

OECD. 2018. "PISA for Development Technical Report." Paris: OECD.

Song Sopheak. 2012. "Influences on Academic Achievement of Primary School Pupils in Cambodia." Excellence in Higher Education, 3 (2): 79–87.

Song Sopheak. 2015. "Cambodian Teachers' Responses to Child-Centered Instructional Policies: A Mismatch between Beliefs and Practices." Teaching and Teacher Education 50 (2015): 36–45.

Tandon, Prateek, and Tsuyoshi Fukao. 2014. Educating the Next Generation: Improving Teacher Quality in Cambodia. Phnom Penh: World Bank.

UNESCO. 2017. Ensuring Adequate, Efficient and Equitable Finance in Schools in the Asia-Pacific Region. Paris: UNESCO.

World Bank. 2020. "World Development Indicators: Government Expenditure on Education."

Wößmann, Ludger, and Martin West. 2006. "Class-Size Effects in School Systems Around the World: Evidence from Between-Grade Variation in TIMSS." European Economic Review 50 (3): 695–736.

ឧបសម្ព័ន្ធ១៖ ឥទ្ធិពលនៃធនធានសាលារៀនលើលទ្ធផលរៀនសូត្ររបស់សិស្ស

| អថេរ | (1) | (2) | (3) | (4) | (5) | (6) |
|---|---|---|---|---|---|---|
| | ការអាន | | គណិតវិទ្យា | | វិទ្យាសាស្ត្រ | |
| **ធនធានសាលារៀន** | | | | | | |
| សាលានៅទីក្រុង | 7.284 | 6.899* | 12.407** | 9.585** | 2.189 | 1.764 |
| | (4.649) | (3.900) | (5.734) | (4.810) | (3.731) | (3.351) |
| សាលារដ្ឋ | -24.189*** | -16.048*** | -31.205*** | -19.198*** | -18.103*** | -12.101** |
| | (7.062) | (5.861) | (8.716) | (7.237) | (5.668) | (5.051) |
| និយាមថ្នាក់ | 0.324** | 0.015 | 0.502*** | 0.137 | 0.290*** | 0.044 |
| | (0.140) | (0.117) | (0.173) | (0.144) | (0.113) | (0.100) |
| ហេដ្ឋារចនាសម្ព័ន្ធសាលារៀន | 6.413*** | 5.790*** | 4.792* | 4.735** | 3.299* | 3.294** |
| | (2.140) | (1.771) | (2.641) | (2.187) | (1.718) | (1.526) |
| សៀវភៅសិក្សា | -0.798 | 0.688 | 2.339 | 3.548 | 0.007 | 1.241 |
| | (3.631) | (3.006) | (4.480) | (3.711) | (2.914) | (2.589) |
| បង្រៀនតាមសមត្ថភាពសិស្ស | 0.658 | -0.227 | 1.377 | 0.926 | 0.675 | 0.421 |
| | (3.500) | (2.897) | (4.318) | (3.576) | (2.809) | (2.494) |
| ថ្នាក់បំប៉ន | -2.339 | -6.468** | 4.743 | 0.447 | 3.002 | -0.274 |
| | (3.528) | (2.926) | (4.351) | (3.611) | (2.831) | (2.517) |
| បទពិសោធន៍បង្រៀន | 1.307*** | 0.395 | 1.227** | 0.118 | 0.883*** | 0.111 |
| | (0.388) | (0.324) | (0.479) | (0.400) | (0.312) | (0.278) |
| គ្រូមានបរិញ្ញាបត្រ | 0.488*** | 0.064 | 0.596*** | 0.092 | 0.318*** | -0.029 |
| | (0.085) | (0.072) | (0.105) | (0.089) | (0.068) | (0.062) |
| គ្រូមានបង្រៀនគួរក្រៅម៉ោង | 0.075 | -0.084 | 0.238** | 0.050 | 0.155** | 0.021 |
| | (0.098) | (0.082) | (0.121) | (0.101) | (0.079) | (0.070) |
| គ្រូមានការងារទី២ | -0.174* | -0.010 | -0.183 | -0.001 | -0.119 | 0.004 |
| | (0.092) | (0.077) | (0.114) | (0.095) | (0.074) | (0.066) |
| **លក្ខណៈសម្បត្តិរបស់សិស្ស និងគ្រួសារ** | | | | | | |
| ភេទស្រី | | 10.827*** | | -7.470*** | | -1.733 |
| | | (1.462) | | (1.764) | | (1.175) |
| កម្រិតថ្នាក់រៀន | | 17.129*** | | 21.290*** | | 14.723*** |
| | | (0.855) | | (1.033) | | (0.690) |
| ត្រួតថ្នាក់ | | -9.133*** | | -4.586** | | -5.255*** |
| | | (1.714) | | (2.068) | | (1.378) |
| អវត្តមានរយៈពេលយូរ | | -17.191*** | | -18.316*** | | -12.627*** |
| | | (2.917) | | (3.520) | | (2.346) |
| ការងារមានប្រាក់ឈ្នួល | | -10.123*** | | -7.096*** | | -9.474*** |
| | | (2.007) | | (2.422) | | (1.614) |
| ការងាររបស់គ្រួសារ | | -4.886*** | | -4.264** | | -4.040*** |
| | | (1.590) | | (1.919) | | (1.278) |
| ម្តាយចេះអក្សរ | | 6.465*** | | 10.060*** | | 6.092*** |
| | | (1.704) | | (2.056) | | (1.370) |
| ឪពុកចេះអក្សរ | | 7.987*** | | 15.359*** | | 7.748*** |
| | | (1.941) | | (2.342) | | (1.561) |
| ធនធានគ្រួសារ | | 4.219*** | | 7.651*** | | 2.098** |
| | | (1.138) | | (1.374) | | (0.916) |
| **ឥទ្ធិពលចៃដន្យ** (Random Effects) | | | | | | |
| កម្រិតសាលារៀន | 218.921 | 336.559 | 136.16 | 122.426 | 194.359 | 100.789 |
| | (42.566) | (63.900) | (26.053) | (25.782) | (39.613) | (19.187) |
| កម្រិតសិស្ស | 2012.516 | 2897.223 | 1294.406 | 1549.807 | 2264.052 | 1009.826 |
| | (52.919) | (76.163) | (34.001) | (40.724) | (59.479) | (26.505) |
| ICC | 0.098 | 0.104 | 0.095 | 0.073 | 0.079 | 0.09 |
| | (0.017) | (0.018) | (0.016) | (0.014) | (0.015) | (0.015) |
| | | | | | | |
| មេគុណថេរ | 264.122*** | 121.193*** | 253.903*** | 58.878*** | 288.575*** | 174.650*** |
| | (14.286) | (14.387) | (17.629) | (17.638) | (11.466) | (12.140) |
| | | | | | | |
| ចំនួនករណីសំណាក | 3184 | 3184 | 3184 | 3184 | 3184 | 3184 |
| ចំនួនក្រុម | 121 | 121 | 121 | 121 | 121 | 121 |

តួរលេខក្នុងរង្វង់ក្រចកជាលំអៀងស្តង់ដា (standard errors) *** p<0.01, ** p<0.05, * p<0.10

# ការស្វែងយល់ពីចំណេះដឹង និងការចូលរួមសកម្មភាពផ្នែកនយោបាយ របស់យុវជន

## សេចក្ដីផ្ដើម

ការចូលរួមសកម្មភាពផ្នែកនយោបាយ សំដៅដល់សកម្មភាពនានាដែលជួយគាំទ្រ ឬជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅដល់គោលនយោបាយពាក់ព័ន្ធនឹងអភិបាលកិច្ច និងស្ថានភាពរស់នៅរបស់ប្រជាជន (Milbrath and Goel 1977)។ នៅក្នុងឯកសារសិក្សាពីនយោបាយ ការចូលរួមផ្នែកនយោបាយតែងផ្សារភ្ជាប់ទៅនឹងចំណេះដឹងផ្នែកនយោបាយ ឬក៏វិសាលភាពនៃព័ត៌មានពិតជាក់ស្ដែងអំពី នយោបាយ និងរដ្ឋាភិបាល ដូចជាស្ថាប័ននយោបាយ និងអ្នកនយោបាយ ជាដើម។ ការស្រាវជ្រាវពីមុនបានរកឃើញថា ការចូលរួមក្នុងសកម្មភាពនយោបាយរបស់ប្រជាជន វាអាស្រ័យថា តើពួកគាត់មានចំណេះដឹងពីរឿងនយោបាយកម្រិតណា (Delli Carpini and Keeter 1996; Stithorn 2012)។ ការសិក្សាទាំងឡាយដែលផ្ដោតជាពិសេសលើយុវជន តែងផ្សារភ្ជាប់បរិមាណនៃការចូលរួមផ្នែកនយោបាយរបស់គាត់ទៅនឹងកម្រិតនៃចំណេះដឹងផ្នែកនយោបាយ ពោលគឺអ្នកមានកម្រិតចំណេះដឹងផ្នែកនយោបាយតិច តែងមានការចូលរួមផ្នែកនយោបាយតិចទៅតាមនោះដែរ (Niemi and Junn 2005; Milner 2005)។

ប្រទេសកម្ពុជាមានចំនួនប្រជាជនវ័យក្មេងច្រើន ពោលគឺប្រជាពលរដ្ឋប្រមាណ ៦៥% មានអាយុក្រោម ៣០ឆ្នាំ (UNDP 2020) ហើយក្នុងនេះ ប្រមាណ ៣៣% (MoEYS 2011) មានអាយុពី ១៥-៣០ឆ្នាំ ដែលក្នុងរបាយការណ៍នេះហៅថា "យុវជន"។ យុវជនដើរតួនាទីសំខាន់ក្នុងផ្នែកនយោបាយ ហើយការអភិវឌ្ឍប្រទេសអាចសម្រេចទៅបាន លុះត្រាតែ ការចូលរួមសកម្មភាពនយោបាយរបស់យុវជន រួមជាមួយនឹងមនុស្សពេញវ័យ (អាយុលើស ៣០ឆ្នាំ) អាចហុចផលវិជ្ជមានដល់សង្គមជាតិ (Heng et al. 2014)។ យុវជនកម្ពុជាត្រូវបានគេមើលរំលងជាយូរមកហើយនៅក្នុងឆាកនយោបាយ ប៉ុន្តែ សន្ទុះនៃការចូលរួមសកម្មភាពនយោបាយរបស់គាត់ក្នុងទសវត្សរ៍ចុងក្រោយនេះ បានផ្លាស់ប្ដូរបរិយាកាសនយោបាយនៅកម្ពុជា។ ដោយសារការប្រើប្រាស់អ៊ិនធើណិត និងបណ្ដាញសង្គម មានភាពទូលំទូលាយច្រើនជាងមុន យុវជនក៏បានដឹងព័ត៌មាន និងមានបញ្ចេញសម្លេងច្រើន ហើយចូលរួមសកម្មភាពនយោបាយ កាន់តែច្រើនឡើងដែរ។ ក្នុងការបោះឆ្នោតឆ្នាំ២០១៣ មានការចូលរួមសកម្មភាពនយោបាយពីយុវជនយ៉ាងច្រើនមិនធ្លាប់ជួបពីមុន។ តាំងពីពេលនោះមក យុវជនក៏ក្លាយជាចំណុចស្នូលក្នុង គោលនយោបាយរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាច្រើន (OECD Development Center 2017)។

ការសិក្សានេះ មានគោលដៅធ្វើការប្រៀបធៀបចំណេះដឹងផ្នែកនយោបាយរបស់យុវជន ទៅនឹងមនុស្សពេញវ័យ ហើយបន្ទាប់មក សិក្សាពីទំនាក់ទំនងរវាង ចំណេះដឹង នឹងការចូលរួមផ្នែកនយោបាយរបស់យុវជន។ លទ្ធផលរកឃើញអាចជួយស្រាយបំភ្លឺពីរបៀបដែលយុវជនកម្ពុជា ចូលរួមក្នុងសកម្មភាពនយោបាយ និងពីកត្តានានាដែលជះឥទ្ធិពលទៅលើចំណេះដឹង និងសកម្មភាពទាំងនោះរបស់គាត់។ គេក៏អាចទាញយកជាមតិយោបល់ផ្នែកគោលនយោបាយ ដើម្បីព្យាយាមដោះស្រាយបញ្ហានានាដែលរារាំងការទទួលបានព័ត៌មាននយោបាយ និងការចូលរួមសកម្មផ្នែកនយោបាយរបស់យុវជនដែរ។

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើទិន្នន័យអង្កេតពីឆ្នាំ២០១៧ ដល់ ២០១៨ របស់វិទ្យាស្ថាន CDRI។ អង្កេតនេះប្រើសំណាកច្រើនស្រទាប់ នៃអ្នកឆ្លើយសម្ភាសន៍ ១.៦០០នាក់ ដែលជ្រើសយកតាមវិធីចៃដន្យ នៅក្រុងភ្នំពេញ និង ៥ខេត្ត (បាត់ដំបង កំពត ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម)។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៤០,២% ជាបុរស ៥៩,៨% ជាស្ត្រី ២៤,៩% ជាយុវជន ៧៥,១% ជាមនុស្សពេញវ័យ ២៦,៥% រស់នៅទីក្រុង និង ៧៥,៥% រស់នៅជនបទ។ បញ្ជីសំណួររួមមាន ១០១សំណួរពាក់ព័ន្ធនឹង លក្ខណៈប្រជាសាស្ត្ររបស់អ្នកឆ្លើយសម្ភាសន៍ អត្តសញ្ញាណនិងតម្លៃសីលធម៌ ទំនុកចិត្តនិងការគោរពទស្សនវិស័យ ការចូលរួមសកម្មភាពនយោបាយ និង ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (Eng et al. 2019)។

## ចំណេះដឹងផ្នែកនយោបាយរបស់យុវជនកម្ពុជា

ក្រុមស្រាវជ្រាវបានប្រើ ការវិភាគពីរអថេរ (bivariate analysis) លើទិន្នន័យអង្កេត ដើម្បីប្រៀបធៀបចំណេះដឹងផ្នែកនយោបាយរបស់យុវជន ជាមួយនឹងមនុស្សពេញវ័យ។ ការវិភាគបានពិនិត្យជាពិសេសលើ ភាពខុសគ្នានៃមធ្យម (mean difference) លើចំណេះដឹងនៃក្រុមអាយុទាំងពីរ ដោយប្រើ Two-Sample T-Test ។ ក្នុងអង្កេតនេះ គេមានសំណួរពីរទៅកាន់អ្នកឆ្លើយសម្ភាសន៍ ដើម្បីធ្វើតេស្ដចំណេះដឹងរបស់គាត់ ស្ដីពីអ្នកនយោបាយ (សូមប្រាប់ឈ្មោះអ្នកនយោបាយឲ្យបានយ៉ាងតិចបីនាក់ ក្រៅពីនាយករដ្ឋមន្ត្រី) និងចំណេះដឹងពីស្ថាប័ននយោបាយ (សូមប្រាប់ឈ្មោះស្ថាប័នកំពូលទាំងបីនៃរដ្ឋាភិបាល)។ សម្រាប់សំណួរនីមួយៗ គេឲ្យចម្លើយត្រូវ ២ពិន្ទុ ចម្លើយត្រូវខ្លះ ១ពិន្ទុ ចម្លើយខុស ពិន្ទុ០។ គេយកផលបូកនៃចម្លើយទាំងពីរ មកប្រើតំណាងឲ្យ ចំណេះដឹងផ្នែកនយោបាយរបស់អ្នកឆ្លើយសម្ភាសន៍។ លទ្ធផលនៃការវិភាគ ត្រូវបានសង្ខេបក្នុង តារាង១ (សូមមើលឧបសម្ព័ន្ធ១) និង រូបភាព១។

អត្ថបទនេះរៀបរៀងដោយ យ៉ង់ មុនីឧត្តម អ្នកប្រឹក្សាយោបល់, លាង សៀកឡេង អ្នកហាត់ការ និង សូ ហេងវត្តី ជំនួយការស្រាវជ្រាវ, នៃមជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Yang Monyoudom, Leang Seakleng, and So Hengvotey. 2020. “Understanding Political Knowledge and Participation of Cambodian Youth.” *Cambodia Development Review* 24 (1): 7–13។

រូបភាព១៖ ចំណេះដឹងផ្នែកនយោបាយរបស់យុវជន និងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600

រូបភាព២៖ ភាពខុសគ្នាក្នុងការអប់រំ (ថ្នាក់រៀនចប់) រវាងយុវជន នឹងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600

លទ្ធផលរកឃើញបង្ហាញថា យុវជននិងមនុស្សពេញវ័យ មានចំណេះដឹងទាក់ទងនឹងអ្នកនយោបាយប្រហាក់ប្រហែលគ្នា ប៉ុន្តែយុវជនហាក់ដឹងពីស្ថាប័ននយោបាយ ច្រើនជាងមនុស្សពេញវ័យ។ គិតជាមធ្យម យុវជនទំនងមានចំណេះដឹង ផ្នែកនយោបាយល្អជាងមនុស្សពេញវ័យ។ ថ្វីបើទិន្នន័យបង្ហាញថា យុវជនមានចំណេះដឹងល្អជាងមនុស្សពេញវ័យក្តី ប៉ុន្តែចំនួនយុវជនដែលឆ្លើយបានត្រឹមត្រូវ នៅមានភាគរយតិចនៅឡើយ។ ជាក់ស្តែងមានយុវជនត្រឹមតែ ៦៥% ប៉ុណ្ណោះ ដែលផ្តល់ចម្លើយបានត្រឹមត្រូវលើសំណួរ អំពីចំណេះដឹងផ្នែកនយោបាយ និង ២០% លើសំណួរអំពីចំណេះដឹងផ្នែកស្ថាប័ននយោបាយ។

ដើម្បីយល់ពីភាពខុសគ្នាខាងលើនេះ ក្រុមស្រាវជ្រាវបានធ្វើ regression អថេរចំណេះដឹងផ្នែកនយោបាយ ទៅលើអថេរមួយចំនួនទៀត ដូចជា អាយុ (Delli Carpini and Keeter 1996) យេនឌ័រ (Mondak and Anderson 2004) ទីតាំង (Pereira 2011) ប្រាក់ចំណូល (Lind 2011) ការអប់រំ (Delli Carpini and Keeter 1996; Niemi and Junn 2005) និង ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (Pasek et al. 2006)។ ការសិក្សានេះបានកំណត់អថេរ ដូចជា (១) អាយុពី ១៦ ដល់ ៣០ (២) យេនឌ័រមានតម្លៃ ១ សម្រាប់ស្ត្រី និង ០ សម្រាប់បុរស (៣) ទីតាំងមានលេខកូដ ១ សម្រាប់ទីក្រុង និង ០ សម្រាប់ជនបទ (៤) ប្រាក់ចំណូលចាប់ពី ០ ដល់ ១.២០០ម៉ឺនរៀល (៥) ការអប់រំមានតម្លៃ ០ សម្រាប់បឋមសិក្សា ឬទាបជាង, ១ សម្រាប់មធ្យមសិក្សា, ២ សម្រាប់សាកលវិទ្យាល័យ (៦) ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ គឺជាចំនួនម៉ោងសរុបដែលបុគ្គលម្នាក់ៗចំណាយអានសារព័ត៌មានបោះពុម្ព មើលទូរទស្សន៍ និង ប្រើអ៊ិនធើណិតក្នុងមួយថ្ងៃ។ ក្រុមស្រាវជ្រាវបានប្រើ Ordinary Least Squares (OLS) ដើម្បីធ្វើ regression ហើយលទ្ធផលត្រូវបានបង្ហាញក្នុងតារាង២ (សូមមើល ឧបសម្ព័ន្ធ២)។

រូបភាព៣៖ ភាពខុសគ្នាក្នុងការប្រើប្រព័ន្ធផ្សព្វផ្សាយ រវាងយុវជន នឹងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600

ស្រដៀងគ្នានឹងការសិក្សានានាដូចលើកខាងលើដែរ លទ្ធផលរកឃើញបានបង្ហាញថា ការអប់រំ និងការប្រើប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលវិជ្ជមានលើចំណេះដឹងផ្នែកនយោបាយ។ លទ្ធផលនេះអាចបញ្ជាក់បានថា យុវជនមានចំណេះដឹងផ្នែកនយោបាយប្រសើរជាងមនុស្សពេញវ័យ ដោយសារយុវជនមានទំនោរទទួលបានការអប់រំខ្ពស់ (រូបភាព២) និងប្រើប្រព័ន្ធផ្សព្វផ្សាយច្រើនជាងមនុស្សពេញវ័យ (រូបភាព៣)[១]។ ការអប់រំជាមធ្យោបាយមួយដើម្បី ជំរុញមនុស្ស បណ្តុះឲ្យមានចំណូលចិត្ត និងបង្កើនលទ្ធភាពរៀនសូត្រពីនយោបាយ (Delli Carpini and Keeter 1996)។ម្យ៉ាងទៀត យុវជន និងមនុស្សពេញវ័យរាយការណ៍ថា ប្រព័ន្ធផ្សព្វផ្សាយជាប្រភពព័ត៌មាននយោបាយសំខាន់បំផុតរបស់ខ្លួនក្រៅពីក្រុមមនុស្សជិតស្និទ្ធ អាជ្ញាធរ និងអង្គការផ្សេងៗ ហើយអ៊ិនធើណិត ហាក់ដូចមានប្រជាប្រិយភាពខ្លាំង សម្រាប់ក្រុមយុវជន (រូបភាព៤)។ ហេតុនេះហើយ ការចំណាយពេលច្រើនក្នុងការប្រើប្រព័ន្ធផ្សព្វផ្សាយ តែងជួយបង្កើនឱកាសស្វែងរក និងស្គាល់ដឹងពីព័ត៌មានផ្នែកនយោបាយផ្សេងៗ ពោលគឺ ចំណេះដឹងផ្នែកនយោបាយ។

១ របបប្រល័យពូជសាសន៍ ប៉ុល ពត និងសង្គ្រាមស៊ីវិល បានបង្អាក់ការអប់រំនៅកម្ពុជា (IIEP-UNESCO 2011)។ ស្របគ្នានឹងការរីកចម្រើនបច្ចេកវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយ គេអាចយល់បានថា យុវជនដែលជាមនុស្សជំនាន់ថ្មី តែងមានការអប់រំ និងការប្រើប្រព័ន្ធផ្សព្វផ្សាយ បានល្អជាង។

រូបភាព៤៖ ប្រភពព័ត៌មានផ្នែកនយោបាយសម្រាប់យុវជន និងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600, CBOs=អង្គការផ្អែកលើសហគមន៍

រូបភាព៥៖ ទស្សនៈរបស់យុវជនពីសារៈសំខាន់នៃការមានគំនិតយោបល់ឯករាជ្យផ្នែកនយោបាយ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

រូបភាព៦៖ អារម្មណ៍របស់យុវជនពីសេរីភាពផ្នែកនយោបាយនៅក្នុង និងនៅក្រៅអ៊ិនធើណិត




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

យុវជនឆ្លើយសម្ភាសន៍ជាច្រើននាក់ បានប្រាប់ពីអារម្មណ៍ថាមានកង្វះខាតខ្លះនូវសេរីភាពផ្នែកនយោបាយនៅក្នុង និងក្រៅប្រព័ន្ធអ៊ិនធើណិត ដែលអាចរារាំងដល់ការទទួលបានចំណេះដឹងផ្នែកនយោបាយ។ ថ្វីបើមានយុវជន ៩៣% បានឆ្លើយថា ការអាចមានគំនិតយល់ឃើញផ្នែកនយោបាយផ្ទាល់ខ្លួន វាជាការសំខាន់ ប៉ុន្តែមានយុវជនដល់ទៅ ២១% ដែលភ័យខ្លាចក្នុងការស្វែងរកព័ត៌មានផ្នែកនយោបាយក្នុងអ៊ិនធើណិត ៣៤% ភ័យខ្លាចក្នុងការចែករំលែកព័ត៌មាននយោបាយតាមអ៊ិនធើណិត និង ៥៤% ភ័យខ្លាច ក្នុងការពិភាក្សាផ្តល់គំនិតយោបល់ផ្នែកនយោបាយក្រៅអ៊ិនធើណិត (រូបភាព៥)។

យ៉ាងណាមិញ ប្រព័ន្ធនយោបាយនៅកម្ពុជា នៅមានការរឹតត្បិតនៅឡើយ។ ជាឧទាហរណ៍ ការពិភាក្សា និងការជួបប្រជុំផ្នែកនយោបាយ ត្រូវបានហាមឃាត់នៅតាមសាលារៀន (Yong 2005)។ គេក៏ឃើញមានកំណត់ត្រាការគៀបសង្កត់ និងការបង្ក្រាបខ្លាំងក្លាលើការតវ៉ា ក៏ដូចជាការធ្វើបាតុកម្មដោយសន្តិវិធី (Henke 2011; Department of State 2012; COMFREL 2013; LICADHO 2014)។ ហើយថ្វីបើការប្រើអ៊ិនធើណិតយ៉ាងទូលំទូលាយនាបច្ចុប្បន្ន បានធ្វើឲ្យបណ្តាញសង្គមក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការផ្តល់ព័ត៌មានថ្មីទាន់ពេល ការពិភាក្សា និងការប្រមូលមតិគ្នាក្តី ប៉ុន្តែជារឿយៗអ្នកប្រើប្រាស់តែងទទួលនូវ ការគំរាមកំហែងតាមផ្លូវច្បាប់ជាបណ្តឹងអះអាងថា គាត់បានបំពានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន (Sok 2015; Sun 2019)។ បញ្ហាទាំងអស់នេះបានបំផុស និងបន្តការភ័យខ្លាចក្នុងចំណោមយុវជន ធ្វើឲ្យគាត់នៅឃ្លាតឆ្ងាយពីនយោបាយ (Heng et al. 2014)។

## ការចូលរួមសកម្មភាពផ្នែកនយោបាយរបស់យុវជនកម្ពុជា

នៅកម្ពុជា យុវជនចូលរួមយ៉ាងសកម្ម ក្នុងការបោះឆ្នោតថ្នាក់ជាតិ ប៉ុន្តែពួកគាត់មានការចូលរួមតិចតួចប៉ុណ្ណោះ ក្នុងអភិបាលកិច្ចកម្រិតមូលដ្ឋាន ជាពិសេសក្នុងដំណើរការកសាងផែនការអភិវឌ្ឍឃុំ[២]។ យុវជនអ្នកឆ្លើយសម្ភាសន៍ ៩៩% បានទទួលស្គាល់ថា គាត់មើលឃើញការចូលរួមបោះឆ្នោតជាកាតព្វកិច្ច ពោលគឺ គាត់ត្រូវតែទៅបោះឆ្នោត (រូបភាព៧)។ ក្នុងចំណោមយុវជនមានសិទ្ធិបោះឆ្នោត ៨៩% បានទៅបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ ៧១% បានទៅបោះឆ្នោតថ្នាក់ឃុំឆ្នាំ២០១៧ និងមានរហូតដល់ ៩៣% គ្រោងនឹងទៅបោះឆ្នោតថ្នាក់ជាតិដ៏ចម្រូងចម្រាស់នៅឆ្នាំ២០១៨ (ដែលពេលនោះ គណបក្សប្រឆាំងត្រូវបានគេហាមឃាត់) (រូបភាព៨)។ សម្រាប់ការចូលរួមក្នុងអភិបាលកិច្ចនៅកម្រិតមូលដ្ឋាន មានយុវជន ៣៧% បានចូលរួម

២ សម្រាប់ព័ត៌មានបន្ថែមស្តីពី ដំណើរការកសាងផែនការអភិវឌ្ឍន៍ នៅកម្រិតឃុំ សូមអាន "Decentralization" by CDC-CRDB and "Guideline on C/S Development Plan and C/S Investment Program" by Inter-ministerial Working Group.

រូបភាព៧៖ យុវជនមានអារម្មណ៍ថា ខ្លួនមានកាតព្វកិច្ចទៅបោះឆ្នោត




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

រូបភាព៨៖ យុវជនបានទៅបោះឆ្នោត (អាយុមានសិទ្ធិបោះឆ្នោត៖ ១៨ឆ្នាំ)




កំណត់សំគាល់៖ ចំនួនយុវជនមានសិទ្ធិបោះឆ្នោត = 352 ក្នុងចំណោម 398

រូបភាព៩៖ ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចកម្រិតមូលដ្ឋាន




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

រូបភាព១០៖ ការប្រជុំពិគ្រោះយោបល់នៅថ្នាក់ភូមិ និងឃុំ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

ក្នុងការប្រជុំថ្នាក់ភូមិ ១៩% ក្នុងការប្រជុំថ្នាក់ឃុំ ១៣% ក្នុងការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ និង ១០% ក្នុងវេទិកាសាធារណៈ (រូបភាព១០)។ រូបភាព១១ បង្ហាញថា ការចូលរួមរបស់យុវជន ក្នុងសកម្មភាពនយោបាយជាទូទៅ មិនបានញឹកញាប់នោះទេ ដោយមានយុវជនតែ ៧% ប៉ុណ្ណោះ ដែលរាយការណ៍ថា គាត់បានចូលរួមក្នុងសកម្មភាពផ្នែកនយោបាយកាលពីខែមុន។

ក្រុមស្រាវជ្រាវបានប្រើ ម៉ូដែល multivariate regression មួយចំនួនទាក់ទងទៅនឹង ការបោះឆ្នោតរបស់យុវជន ក៏ដូចជាការចូលរួមក្នុងអភិបាលកិច្ចនៅកម្រិតមូលដ្ឋានរបស់គាត់ ដើម្បីពន្យល់ពីទំនាក់ទំនងជាទូទៅរវាង ចំណេះដឹង និងការចូលរួមផ្នែកនយោបាយរបស់យុវជន។ ក្នុងម៉ូដែលទាំងនេះ គ្រប់លំនាំនៃការបោះឆ្នោតរបស់យុវជន និងការចូលរួមរបស់គាត់នៅថ្នាក់ភូមិនិងឃុំ ត្រូវបានគេចាត់ទុកជា អថេរពឹងផ្អែក (dependent

រូបភាព១១៖ ការចូលរួមរបស់យុវជននៅខែមុន




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

variables) ហើយអថេរនីមួយៗត្រូវបានគេលើកយកមកសិក្សាដាច់ដោយឡែកពីគ្នា។ អថេរពឹងផ្អែកទាំងអស់ ត្រូវបានគេវាស់វែងស្របតាមចម្លើយរបស់យុវជន ទៅនឹងសំណួរស្ទង់មតិដែលជាប់ទាក់ទងគ្នានោះ ពោលគឺមាន តម្លៃ ១ សម្រាប់ការបានចូលរួម និង 0 សម្រាប់ការមិនបានចូលរួម។ នៅក្នុងម៉ូដែលទាំងនេះ ក៏មានចំណេះដឹងផ្នែកនយោបាយជាអថេរឯករាជ្យ (independent variable) ចម្បង ហើយចំពោះអថេរដទៃទៀត ដូចជា អាយុ យេនឌ័រ ទីតាំង ប្រាក់ចំណូល ការអប់រំ និង ការប្រើប្រព័ន្ធផ្សព្វផ្សាយ គឺត្រូវបានគេត្រួតពិនិត្យ ព្រោះឯកសារស្រាវជ្រាវពីមុនៗ បានបញ្ជាក់ថា អថេរទាំងនេះ អាចជះឥទ្ធិពលខ្លះទៅលើការចូលរួមផ្នែកនយោបាយរបស់បុគ្គលនីមួយៗ (Stithorn 2012; Adegbola and Gearhart 2019)។ ដោយហេតុថា អថេរពឹងផ្អែកទាំងអស់ សុទ្ធសឹងជា អថេរគោលពីរ (binary variables) ដូច្នេះ ក្រុមស្រាវជ្រាវបានប្រើវិធី logistic regression ដើម្បីអាចសិក្សាម៉ូដែលទាំងអស់បាន ដូចមានចុះក្នុង តារាង៣ (សូមមើលឧបសម្ព័ន្ធ៣)។

លទ្ធផលបង្ហាញថា ចំណេះដឹងផ្នែកនយោបាយ មានមេគុណវិជ្ជមាន (positive coefficients) ដែលអាចយកជាការបានសម្រាប់គ្រប់លំនាំនៃ ការចូលរួមសកម្មភាពផ្នែកនយោបាយទាំងអស់ លើកលែងតែការបោះឆ្នោតនៅថ្នាក់ជាតិ និងការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ។ ចំណុចនេះមានន័យថា យុវជនដែលមានចំណេះដឹងផ្នែកនយោបាយច្រើន រមែងតែងចូលរួមច្រើនដែរក្នុងការបោះឆ្នោតថ្នាក់ឃុំ និង ការប្រជុំពិគ្រោះយោបល់នៅថ្នាក់ភូមិ និងឃុំ លើកលែងតែ ការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ។ និយាយដោយខ្លី ការមានចំណេះដឹងច្រើនផ្នែកនយោបាយ នាំឲ្យមានការចូលរួមផ្នែកនយោបាយច្រើនដូចគ្នា។ ប៉ុន្តែបើនិយាយពីទំនាក់ទំនង ជាហេតុនិងផល រវាងចំណេះដឹងនឹងការចូលរួមផ្នែកនយោបាយតែម្ដង គឺវាពុំមានភាពច្បាស់លាស់នោះទេ ព្រោះទំនាក់ទំនងនេះអាចមានទាំងពីរទិស (ទៅ-មក)។ ជាក់ស្ដែង ចំណេះដឹងផ្នែកនយោបាយច្រើន អាចលើកទឹកចិត្តយុវជន ឲ្យចូលរួមសកម្មភាពផ្នែកនយោបាយច្រើន ប៉ុន្តែយុវជនក៏អាចទទួលបានចំណេះដឹងកាន់តែច្រើនដែរ តាមរយៈការចូលរួមសកម្មភាពផ្នែកនយោបាយជាច្រើនរបស់គាត់។ ទោះបីជាវាពិបាក ក្នុងការកំណត់ទិសដៅនៃទំនាក់ទំនង ជាហេតុនិងផល រវាងចំណេះដឹង នឹងការចូលរួមសកម្មភាពផ្នែកនយោបាយរបស់យុវជនឲ្យបានច្បាស់លាស់ក្តី យុវជនទាំងឡាយគប្បីត្រូវមានចំណេះដឹងជាមូលដ្ឋានផ្នែកនយោបាយ ដើម្បីអាចចូលរួមជាប្រយោជន៍ដល់សង្គមនយោបាយនៅកម្ពុជា (Milner 2002)។

## សេចក្តីសន្និដ្ឋាន

តាមការធ្វើវិភាគដោយប្រើ ពីរអថេរ និង ច្រើនអថេរ នេះ ក្រុមស្រាវជ្រាវបានរកឃើញថា យុវជនកម្ពុជាតែងដឹងព័ត៌មានផ្នែកនយោបាយ បានប្រសើរជាងមនុស្សជំនាន់មុន។ ចំណេះដឹងច្រើនជាងផ្នែកនយោបាយនេះ វាជាប់ទាក់ទងនឹងការអប់រំខ្ពស់ជាង និងការប្រើប្រព័ន្ធផ្សព្វផ្សាយច្រើនជាងរបស់យុវជន ដែលជួយឲ្យពួកគាត់អាចទទួលបាន ព័ត៌មានជាក់ស្តែងផ្នែកនយោបាយផ្សេងៗ យ៉ាងច្រើន។ លទ្ធផលបែបនេះ ជាសញ្ញាលើកទឹកចិត្តមួយដល់ការអភិវឌ្ឍផ្នែកនយោបាយនៅកម្ពុជា ព្រោះយុវជន គឺជាក្រុមនយោបាយចម្បងមួយ ហើយពួកគាត់មានការចាប់អារម្មណ៍ទៅលើនយោបាយ និងមិនចូលរួមសកម្មភាពនយោបាយនានាទាំងងងឹតងងល់ ដូចលទ្ធផលរកឃើញបានបង្ហាញថា នៅពេលយុវជនមានចំណេះដឹងផ្នែកនយោបាយកាន់តែច្រើន ពួកគាត់តែងចូលរួមនៅក្នុងសកម្មភាពនយោបាយកាន់តែច្រើនដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ នៅមានយុវជនជាច្រើននាក់ដែរដែលនៅខ្វះចំណេះដឹងផ្នែកនយោបាយ ហើយគួបផ្សំនឹងអារម្មណ៍ថាខ្វះសិទ្ធិសេរីភាពផ្នែកនយោបាយទៀតផងនោះ ការចូលរួមផ្នែកនយោបាយរបស់ពួកគាត់ នឹងមានកកម្រិត។ ហេតុនេះហើយ រដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលជាប់ពាក់ព័ន្ធទាំងឡាយ គួររួមសហការគ្នា កសាងបរិយាកាសនយោបាយអំណោយផលមួយ ដែលយុវជនអាចទទួលអារម្មណ៍ថា ខ្លួនមានសិទ្ធិអំណាចមិនមែនភ័យខ្លាចក្នុងការស្វែងរកព័ត៌មានផ្នែកនយោបាយ និងចូលរួមជាប្រយោជន៍នៅក្នុងសកម្មភាពនយោបាយនោះទេ។

ការស្រាវជ្រាវនេះ នៅមានកង្វះខាតខ្លះដែលការសិក្សានាពេលអនាគតគួរជួយដោះស្រាយ។ ចំណេះដឹងផ្នែកនយោបាយជាគោលគំនិតមួយយ៉ាងធំទូលាយ ដែលក្តោបរាល់ព័ត៌មានជាក់ស្តែងផ្នែកនយោបាយផ្សេងៗ ប៉ុន្តែសូចនាករនៃចំណេះដឹងផ្នែកនយោបាយ ដែលត្រូវបានយកមកប្រើក្នុងការវិភាគនេះ ផ្អែកលើតែ ២សំណួរ ស្តីពី ចំណេះដឹងផ្នែកនយោបាយប៉ុណ្ណោះ ដែលអាចធ្វើឲ្យកត្តាតាង (proxy) មិនអាចវាស់វែងបានត្រឹមត្រូវនូវចំណេះដឹងផ្នែកនយោបាយជាទូទៅរបស់យុវជន។ ទិន្នន័យអង្កេតទៀតសោត ក៏ស្រង់បានតាំងពីចុងឆ្នាំ២០១៧ ដល់ដើមឆ្នាំ២០១៨ មកម្ល៉េះ។ ដោយហេតុថា តាំងពីពេលនោះមក ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ក៏ដូចជាសង្គមនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយ វាបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលអាចធ្វើឲ្យប្រែប្រួលដល់ឥរិយាបថ និងសកម្មភាពផ្នែកនយោបាយរបស់យុវជននៅឆ្នាំ២០២០ នេះ។

## ឯកសារយោង

Adegbola, Oluseyi and Sherice Gearhart. 2019. *International Journal of Communication* 13(2019): 1231-1251.

CDC-CDRD. 2002. "Decentralization." http://www.cdc-crdb.gov.kh/cdc/ngo_statement/decentralization.htm, accessed 26 Mar 2020.

COMFREL. 2013. *Democracy, Elections, and Reform in Cambodia*. 2012 Annual Report. Phnom Penh: COMFREL.

Delli Carpini, M. and S. Keeter. 1996. *What Americans Know about Politics and Why It Matters*. New Haven, CT: Yale University Press.

Department of State. 2012. *Cambodia 2012 Human Rights Report*. Country Report. Washington DC: Department of State.

Eng Netra, Ang Len, So Hengvotey, Hav Gechhong and Chhom Theavy. 2019. *Cambodia's Young and Older Generation: Views on Generational Relations and Key Social and Political Issues*. Working Paper Series No. 116. Phnom Penh: CDRI.

Heng Seiha, Vong Mun and Chheat Sreang. 2014. *The Enduring Gap: Decentralization Reform and Youth Participation in Local Rural Governance*. Working Paper Series No. 94. Phnom Penh: CDRI.

Henke, Roger. 2011. "NGOs, People's Movements and Natural Resource Management." In *Cambodia's Economic Transformation,* edited by Caroline Hughes and Kheang Un, 288-309. Copenhagen: NIAS Press.

IIEP-UNESCO. 2011. *Education and Fragility in Cambodia*. IIEP Research Paper. Paris: IIEP-UNESCO.

Inter-ministerial Working Group. 2007. *Guideline on C/S Development Plan and C/S Investment Program*. Phnom Penh: Inter-ministerial Working Group.

LICADHO. 2014. *Human Rights 2013: The Year in Review*. Human Rights Report. Phnom Penh: LICADHO.

Lind, Jo Thori and Dominic Rohner. 2011. *Knowledge is Power: A Theory of Information, Income, and Welfare Spending*. Working Paper Series No. 36. Zürich: Department of Economics at University of Zürich.

Milbrath, Lester W. and Manda La Goel. 1977. *Political Participation: How and Why People Get Involved in Politics*. Chicago: Rand McNally.

Milner, Henry. 2002. "Civic Literacy: How Informed Citizens Make Democracy Work." *Canadian Journal of Political Science* 36 (3): 676-679.

Milner, Henry. 2005. "Are Young Canadians Becoming Political Dropouts? A Comparative Perspective." *IRPP Choices* 11 (3): 1-26.

MoEYS. 2011. *National Policy on Youth Development*. Phnom Penh: MoEYS.

Mondak, J. and M. Anderson. 2004. "The Knowledge Gap: A Reexamination of Gender based Differences in Political Knowledge." *Journal of Politics* 66: 492-512.

Niemi, Richard and Jane Junn. 2005. *Civic Education: What Makes Students Learn*. New Haven: Yale University Press.

OECD Development Center. 2017. *Youth Well-being Policy Review of Cambodia*. Report for the EU-OECD Youth Inclusion Project Country Review. Paris: OECD Development Center.

Pasek, Josh, Romer Dan and Kate Kenski. 2006. "America's Youth and Community Engagement: How Use of Mass Media Is Related to Civic Activity and Political Awareness in 14- to 22-Year-Olds." *Community Research* 33 (3): 115-135.

Pereira, Federico Batista. 2011. *Politcal Knowledge Levels across the Urban-Rural Divide in Latin America and the Caribbean*. Latin American Public Opinion Project, AmericasBarometer Insights Series No. 68. Nashville: Vanderbilt University.

Sok Khemara. 2015. "Media Experts Warn against a Cyber-crime Law that Hurts Online Freedom." *VOA Cambodia*. 12 Oct 2015. https://www.voacambodia.com/a/media-experts-warn-against-a-cyber-crime-law-that-hurts-online-freedom/3002439.html.

Stithorn Thananithichot. 2012. "Political Engagement and Participation of Thai Citizens: The Rural-Urban Disparity." *Contemporary Politics* 18 (1): 87-108.

Sun Narin. 2019. "Cambodia Takes Aim Critics Who Post on Facebook." *VOA Cambodia*. 16 Mar 2019. https://www.voanews.com/east-asia-pacific/cambodia-takes-aim-critics-who-post-facebook.

UNDP. 2020. "About Cambodia." https://www.kh.undp.org/content/cambodia/en/home/countryinfo.html#Introduction, accessed 27 Apr 2020.

Yong Kim Eng. 2005. *Force of the Future? Youth Participation in Politics in Cambodia*. Country Paper in Go! Young Progressives in Southeast Asia. Manila: Beate Martin, FES Philippines Office.

## ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ ១

តារាង១៖ ភាពខុសគ្នាក្នុងចំណេះដឹងពីនយោបាយ រវាងយុវជន នឹងមនុស្សពេញវ័យ

| អថេរ | យុវជន | មនុស្សពេញវ័យ | តួលេខខុសគ្នា |
|---|---|---|---|
| ចំណេះដឹងនយោបាយ | | | |
| អ្នកនយោបាយ | 1.49 | 1.5241 | 0.0342 |
| | (0.0381) | (0.0214) | (0.0437) |
| ស្ថាប័ន | 0.5151 | 0.3353 | 0.1798*** |
| | (0.0404) | (0.0196) | (0.0448) |
| សរុប | 2.005 | 1.8594 | 0.1456** |
| | (0.0623) | (0.0328) | (0.0705) |

កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600
Standard errors are reported in brackets.
* * * denotes P-value < 0.01, * * denotes P-value < 0.05.

## ឧបសម្ព័ន្ធ ២

តារាង២៖ លទ្ធផលការធ្វើ OLS regression លើកត្តាប៉ះពាល់ដល់ចំណេះដឹងផ្នែកនយោបាយ

| អថេរ | មេគុណ (coefficient) |
|---|---|
| អាយុ | 0.0038** |
| | (0.0019) |
| យេនឌ័រ/ស្ត្រី | -0.4898*** |
| | (0.0552) |
| ទីតាំង/ទីក្រុង | 0.1154* |
| | (0.0614) |
| ប្រាក់ចំណូល | 0.0106 |
| | (0.0124) |
| ការអប់រំ | 0.6888*** |
| | (0.0502) |
| ការប្រើប្រព័ន្ធផ្សព្វផ្សាយ | 0.0487*** |
| | (0.01) |

កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,594
សង្កេតមានបាត់ខ្លះដោយសារព័ត៌មានទទួលបានមិនពេញលេញ
Robust standard errors ចុះក្នុងវង្វង់ក្រចក
* * * denotes P-value < 0.01, * * denotes P-value < 0.05, * denotes P-value <0.1.

## ឧបសម្ព័ន្ធ ៣

តារាង៣៖ លទ្ធផលនៃ Logistic regression លើទំនាក់ទំនងរវាងចំណេះដឹង នឹងការចូលរួមផ្នែកនយោបាយរបស់យុវជន

| អថេរ | ការបោះឆ្នោតក្នុងពេលបោះឆ្នោត | | | ការចូលរួមនៅថ្នាក់ភូមិ និងឃុំ | | | |
|---|---|---|---|---|---|---|---|
| | ថ្នាក់ជាតិ ឆ្នាំ២០១៣ | ថ្នាក់ឃុំ ឆ្នាំ២០១៧ | ថ្នាក់ជាតិ ឆ្នាំ២០១៨ (រំពឹងទុក) | ការប្រជុំថ្នាក់ភូមិ | ការប្រជុំថ្នាក់ឃុំ | ការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ | វេទិកាសាធារណៈ |
| ចំណេះដឹងផ្នែកនយោបាយ | 0.2052 | 0.2087** | 0.1917 | 0.2913*** | 0.2792** | 0.0155 | 0.2896* |
| | (0.1555) | (0.1065) | (0.148) | (0.107) | (0.116) | (0.1351) | (0.1801) |
| អាយុ | 0.485*** | 0.2633*** | 0.2464*** | 0.1456*** | 0.0926*** | 0.0388 | 0.1154** |
| | (0.0457) | (0.0327) | (0.0495) | (0.0285) | (0.0328) | (0.0411) | (0.0487) |
| យេនឌ័រ/ស្ត្រី | 0.4054 | 0.3297 | -0.0398 | -0.1138 | -0.0143 | -0.2931 | -0.0431 |
| | (0.3158) | (0.2616) | (0.3493) | (0.2416) | (0.2786) | (0.3073) | (0.3403) |
| ទីតាំង/ទីក្រុង | 0.3933 | 0.0358 | -0.0357 | -0.6127* | -0.1156 | -0.1293 | -0.3662 |
| | (0.4171) | (0.3286) | (0.4716) | (0.321) | (0.3734) | (0.4544) | (0.4731) |
| ប្រាក់ចំណូល | 0.1058* | 0.1012* | 0.0949 | -0.1039* | 0.048 | 0.0341 | 0.0087 |
| | (0.0662) | (0.0586) | (0.0673) | (0.0572) | (0.0706) | (0.0728) | (0.0867) |
| ការអប់រំ | 0.5178* | 0.6667*** | 0.0658 | -0.7142*** | -0.3942* | -0.166 | -0.1438 |
| | (0.275) | (0.232) | (0.3318) | (0.2206) | (0.2675) | (0.3203) | (0.3372) |
| ការប្រើប្រព័ន្ធផ្សព្វផ្សាយ | -0.01 | -0.0015 | 0.0796 | 0.0044 | -0.0063 | -0.0456 | 0.0596 |
| | (0.0537) | (0.0455) | (0.071) | (0.0398) | (0.0467) | (0.0586) | (0.057) |
| N | 398 | 398 | 398 | 398 | 398 | 398 | 398 |
| Pseudo R-squared | 0.4386 | 0.2434 | 0.1809 | 0.1116 | 0.0474 | 0.0167 | 0.0477 |
| Wald Chi-square | 129.82 | 98.38 | 31.09 | 49.87 | 19.83 | 6.08 | 9.8 |
| P-value | 0.0000 | 0.0000 | 0.0001 | 0.0000 | 0.0059 | 0.5308 | 0.1999 |

កំណត់សំគាល់៖ N គឺជាចំនួនសង្កេតឃើញ
Robust standard errors are reported in brackets.
* * * denotes P-value < 0.01, * * denotes P-value < 0.05, * denotes P-value < 0.1.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៤ ឆ្នាំ២០១៩ ។

ធៀបនឹងកាលពីមួយឆ្នាំមុន កំណើន ផសស ពិត ក្នុងប្រទេសអាស៊ានជ្រើសរើសទាំងប្រាំ បានធ្លាក់ចុះ ពោលគឺ ធ្លាក់ចុះ ០,២% នៅឥណ្ឌូនេស៊ី ១,១% នៅម៉ាឡេស៊ី ១,៤% នៅសិង្ហបុរី ២,១% នៅថៃ និង ០,៦% នៅវៀតណាម។ បើធៀបនឹងត្រីមាសមុន កំណើន ផសស នៅឥណ្ឌូនេស៊ីនៅថេរត្រឹម ៥,០% នៅសិង្ហបុរី វាកើន ០,៣ឯកតាភាគរយ ដល់ ០,៨% ហើយនៅក្នុងពីរប្រទេសទៀត គឺ ម៉ាឡេស៊ី និង ថៃ វា ធ្លាក់ចុះអស់ ០,៨ឯកតាភាគរយដូចគ្នា។ គួរកត់សំគាល់ថា ថ្វីបើមានការធ្លាក់ចុះធៀបនឹងត្រីមាសមុនក្តី ប៉ុន្តែកំណើន ផសស នៅវៀតណាមនៅតែខ្ពស់ជាងគេក្នុងក្រុមប្រទេសជ្រើសរើសនេះ បន្ទាប់មកគឺ ឥណ្ឌូនេស៊ី ដែលមានកំណើន ផសស នៅថេរក្នុងបីត្រីមាសចុងក្រោយ បន្ទាប់ពីបានធ្លាក់ចុះបន្តិចនៅត្រីមាសទី១ ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើសទាំងបួន កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះនៅ ចិន និង ហុងកុង ប៉ុន្តែវាកើនឡើងនៅ កូរ៉េខាងត្បូង និង តៃវ៉ាន់។ កំណើននៅចិន ធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ ដល់ ៦.០% ហើយនៅហុងកុង ធ្លាក់ចុះ ៤,២ឯកតាភាគរយ ដល់ -២,៩%។ នៅកូរ៉េខាងត្បូង កំណើន ផសស កើនបាន ០,២ឯកតាភាគរយ ដល់ ៣,៤% និងនៅតៃវ៉ាន់ វាកើន ១,៥ឯកតាភាគរយ ដល់ ៣,៣%។ បើធៀបនឹងត្រីមាសមុន មានតែកំណើននៅហុងកុងប៉ុណ្ណោះ ដែលបានធ្លាក់ចុះអស់ ៥,៨ ឯកតាភាគរយ រីឯនៅចិន វានៅថេរ នៅកូរ៉េខាងត្បូង វាកើន ១,៤ឯកតាភាគរយ ហើយនៅតៃវ៉ាន់ វាកើន ០,៣ឯកតាភាគរយ។

ធៀបនឹងកាលពីមួយឆ្នាំមុន កំណើន ផសស ពិត ក្នុងប្រទេសឧស្សាហកម្មជ្រើសរើសទាំងបី (តំបន់អឺរ៉ូ១២ ជប៉ុន និង សហរដ្ឋអាមេរិក) បានធ្លាក់ចុះ ពោលគឺ នៅតំបន់អឺរ៉ូ១២ វាបានធ្លាក់ចុះអស់ ០,១ឯកតាភាគរយ ដល់ ១,០% នៅជប៉ុន វាធ្លាក់ចុះ ១,១ឯកតាភាគរយ ដល់ -០,៧% និងនៅសហរដ្ឋអាមេរិក វាធ្លាក់ចុះ ០,៨ឯកតាភាគរយ ដល់ ២,៣%។ ធៀបនឹងត្រីមាសមុន មានតែសហរដ្ឋអាមេរិកប៉ុណ្ណោះ ដែលមានកំណើន ផសស កើនបាន ០,២ឯកតាភាគរយ រីឯនៅតំបន់អឺរ៉ូ១២ កំណើន ផសស បានធ្លាក់ចុះ ០,២ឯកតាភាគរយ ហើយនៅជប៉ុន វាធ្លាក់ចុះ ២,៤ឯកតាភាគរយ។

## អតិផរណាក្នុងពិភពលោក

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អតិផរណានៅ កម្ពុជា ឥណ្ឌូនេស៊ី និង ថៃ បានធ្លាក់ចុះ រីឯនៅ ម៉ាឡេស៊ី សិង្ហបុរី និង វៀតណាម វាកើនឡើង។ នៅកម្ពុជា អត្រាអតិផរណាបានធ្លាក់ចុះ ០,៣ឯកតាភាគរយ ដល់ ២,១% នៅឥណ្ឌូនេស៊ី វាធ្លាក់ចុះ ០,៣ ឯកតាភាគរយ ដល់ ២,៩% និងនៅថៃ ធ្លាក់ចុះ ០,៤ឯកតាភាគរយ ដល់ ០,៤% ប៉ុន្តែនៅម៉ាឡេស៊ី វាកើន ០,៧ឯកតាភាគរយ ដល់ ១,០% នៅសិង្ហបុរី កើន ០,១ឯកតាភាគរយ ដល់ ០,៦% និងនៅវៀតណាម កើន ០,៣ឯកតាភាគរយ ដល់ ៣,៧%។ ធៀបនឹងត្រីមាសមុន នៅកម្ពុជាអត្រាអតិផរណាកើន ០,១ឯកតាភាគរយ នៅសិង្ហបុរី វាកើន ០,១ឯកតាភាគរយ និងនៅវៀតណាម កើន ១,៥ឯកតាភាគរយ ប៉ុន្តែនៅឥណ្ឌូនេស៊ី វាធ្លាក់ចុះអស់ ០,៥ ឯកតាភាគរយ នៅម៉ាឡេស៊ី ធ្លាក់ចុះ ០,៣ឯកតាភាគរយ និង នៅថៃ ធ្លាក់ចុះ ០,២ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាអតិផរណានៅចិន កើន ២,១ឯកតាភាគរយ ដល់ ៤,៣% និងនៅហុងកុង វាកើន ០,៤ឯកតាភាគរយ ដល់ ៣,០%។ អត្រាអតិផរណានៅកូរ៉េខាងត្បូង ធ្លាក់ចុះ ០,៩ឯកតាភាគរយ ដល់ ០,៣% និងនៅតៃវ៉ាន់ វាធ្លាក់ចុះ ០,២ឯកតាភាគរយ ដល់ ០,៧%។ ធៀបនឹងត្រីមាសមុន មានតែហុងកុងទេ ដែលមានអត្រាអតិផរណាធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ រីឯអត្រាអតិផរណានៅចិន កើន ១,៤ឯកតាភាគរយ នៅកូរ៉េខាងត្បូង វាកើន ០,២ឯកតាភាគរយ និងនៅតៃវ៉ាន់ កើន ០,៣ឯកតាភាគរយ។

ពីមួយឆ្នាំទៅមួយឆ្នាំ អត្រាអតិផរណាក្នុងប្រទេសឧស្សាហកម្មជ្រើសរើសទាំងបី បានធ្លាក់ចុះ ដោយនៅតំបន់អឺរ៉ូ១២ វាធ្លាក់ចុះ ០,៩ឯកតាភាគរយ ដល់ ១,០% នៅជប៉ុន វាធ្លាក់ចុះ ០,៤ឯកតាភាគរយ ដល់ ០,៥% និង នៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ០,១ ឯកតាភាគរយ ដល់ ២,១%។ ប៉ុន្តែបើធៀបនឹងត្រីមាសមុន អត្រាអតិផរណានៅតំបន់អឺរ៉ូ១២ នៅថេរត្រឹម ១,០% នៅជប៉ុន វាកើន ០,២ឯកតាភាគរយ និងនៅសហរដ្ឋអាមេរិក កើន ០,៤ ឯកតាភាគរយ។

## អត្រាប្តូរប្រាក់

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលបានចុះថ្លៃ ០,៤% ដល់ ៤.០៦៣,៧រៀល/ដុល្លារ។ ប្រាក់ដុល្លារសិង្ហបុរី នៅថេរត្រឹម ១,៤ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក តាំងពីត្រីមាសទី៣ ឆ្នាំ២០១៨ មក។ ប្រាក់បាតថៃបានឡើងថ្លៃ ៧.៦% ដល់ ៣០,៣បាត/ដុល្លារ ប៉ុន្តែប្រាក់ដុងវៀតណាមបានចុះថ្លៃ ២,១% ដល់ ២៣.២១៧,៣ដុង/ដុល្លារ។ បើធៀបនឹងត្រីមាសមុន ប្រាក់រៀលបានឡើងថ្លៃ ០,៦% ប្រាក់បាតថៃឡើងថ្លៃ ១,៣% ប៉ុន្តែប្រាក់ដុងវៀតណាមបានចុះថ្លៃ ០,២%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ពោតបានឡើងថ្លៃ ២,៥% ប្រេងដូងប្រេងឡើងថ្លៃ ២២,៦% កៅស៊ូឡើងថ្លៃ ៨,២% អង្ករឡើងថ្លៃ ៣,៨% និងសាំងឡើងថ្លៃ ០,៩៣% ប៉ុន្តែសណ្តែកសៀងបានចុះថ្លៃ ៥,៩% ប្រេងឆៅចុះថ្លៃ ១០,៣% និង ម៉ាស៊ូតចុះថ្លៃ ៥,៤%។ ធៀបនឹងត្រីមាសមុន ប្រេងដូងប្រេងឡើងថ្លៃ ១៩,៣% កៅស៊ូឡើងថ្លៃ ១,៥% អង្ករឡើងថ្លៃ ០,៧% សណ្តែកសៀងឡើងថ្លៃ ២,២% ប្រេងឆៅឡើងថ្លៃ ១,០% ប៉ុន្តែពោតចុះថ្លៃ ១,៩% និងសាំងចុះថ្លៃ ៥,៨%។ គួរកត់សំគាល់ថា ពោត និងសាំង បានចុះថ្លៃរហូតតាំងពីត្រីមាសទី២ ឆ្នាំ២០១៩ មក រីឯថ្លៃទំនិញឯទៀតបានឡើងចុះ។

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០១៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.1 | 7.0 | 7.0 | 7.0 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.2 | 4.8 | 5.0 | 5.1 | 5.1 | 5.3 | 5.2 | 5.2 | 5.1 | 5.0 | 5.0 | 5.0 |
| ម៉ាឡេស៊ី | 6.0 | 4.9 | 4.3 | 5.9 | 5.4 | 4.5 | 4.4 | 4.7 | 4.5 | 4.9 | 4.4 | 3.6 |
| សិង្ហបុរី | 3.0 | 2.0 | 2.0 | 3.8 | 4.4 | 3.9 | 2.2 | 2.2 | 1.3 | 0.1 | 0.5 | 0.8 |
| ថៃ | 1.6 | 2.8 | 3.2 | 3.8 | 4.8 | 4.6 | 3.3 | 3.7 | 2.8 | 2.3 | 2.4 | 1.6 |
| វៀតណាម | 5.9 | 6.6 | 6.1 | 6.6 | 7.4 | 6.8 | 6.9 | 7.6 | 6.8 | 6.7 | 7.3 | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.3 | 7.0 | 6.7 | 6.9 | 6.8 | 6.7 | 6.5 | 6.4 | 6.4 | 6.2 | 6.0 | 6.0 |
| ហុងកុង | 2.3 | 2.3 | 1.7 | 2.8 | 4.7 | 3.5 | 2.9 | 1.3 | 0.6 | 0.5 | 2.9 | -2.9 |
| កូរ៉េខាងត្បូង | 3.4 | 2.6 | 2.6 | 3.0 | 2.8 | 2.9 | 3.2 | 3.2 | 1.8 | 2.1 | 2.0 | 3.4 |
| តៃវ៉ាន់ | 3.5 | 0.6 | 1.2 | 2.8 | 3.0 | 3.3 | 2.3 | 1.8 | 1.7 | 2.4 | 3.0 | 3.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.7 | 1.3 | 1.6 | 2.3 | 2.5 | 2.2 | 1.6 | 1.1 | 1.2 | 1.1 | 1.2 | 1.0 |
| ជប៉ុន | 0.6 | 0.3 | 0.9 | 1.8 | 1.1 | 1.0 | 0 | 0.4 | 0.9 | 1.2 | 1.7 | -0.7 |
| សហរដ្ឋអាមេរិក | 2.4 | 2.3 | 1.6 | 2.3 | 2.8 | 2.9 | 3.0 | 3.1 | 3.2 | 2.3 | 2.1 | 2.3 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០១៩ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.9 | 1.2 | 3.0 | 2.9 | 2.2 | 2.7 | 2.5 | 2.4 | 1.9 | 1.8 | 2.0 | 2.1 |
| ឥណ្ឌូនេស៊ី | 6.4 | 6.4 | 3.5 | 3.8 | 3.3 | 3.2 | 3.1 | 3.2 | 2.6 | 3.1 | 3.4 | 2.9 |
| ម៉ាឡេស៊ី | 3.2 | 2.1 | 2.1 | 3.9 | 1.8 | 1.3 | 0.4 | 0.3 | -0.3 | 0.6 | 1.3 | 1.0 |
| សិង្ហបុរី | 1.0 | -0.5 | -0.8 | 0.6 | 0.2 | 0.4 | 0.7 | 0.5 | 0.5 | 0.8 | 0.5 | 0.6 |
| ថៃ | 1.9 | -0.9 | 0.2 | 0.7 | 0.6 | 1.3 | 1.5 | 0.8 | 0.7 | 1.1 | 0.6 | 0.4 |
| វៀតណាម | 4.8 | 0.6 | 2.7 | 3.4 | 2.8 | 3.8 | 4.5 | 3.4 | 2.6 | 2.7 | 2.2 | 3.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.0 | 1.4 | 2.0 | 1.6 | 2.2 | 1.8 | 2.3 | 2.2 | 1.8 | 2.6 | 2.9 | 4.3 |
| ហុងកុង | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.1 | 2.3 | 2.6 | 2.2 | 2.7 | 3.4 | 3.0 |
| កូរ៉េខាងត្បូង | 1.3 | 0.7 | 0.8 | 2.0 | 1.2 | 1.5 | 1.6 | 1.2 | 0.6 | 0.7 | 0.1 | 0.3 |
| តៃវ៉ាន់ | 1.5 | 0.6 | 1.4 | 0.6 | 1.6 | 1.6 | 1.6 | 0.9 | 0.3 | 0.8 | 0.4 | 0.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.4 | 0.0 | 0.3 | 1.5 | 1.3 | 1.7 | 2.1 | 1.9 | 1.4 | 1.4 | 1.0 | 1.0 |
| ជប៉ុន | 2.8 | 0.9 | -0.1 | 0.6 | 1.3 | 0.6 | 1.1 | 0.9 | 0.3 | 0.7 | 0.3 | 0.5 |
| សហរដ្ឋអាមេរិក | 1.6 | 0.0 | 1.2 | 2.1 | 2.2 | 2.7 | 2.6 | 2.2 | 1.7 | 1.8 | 1.7 | 2.1 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.6 | 4060.4 | 4053.6 | 4047.0 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 | 4063.7 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 11850.2 | 13394.8 | 13338.3 | 13379.8 | 13576.1 | 13944.6 | 14600.2 | 14789.7 | 14127.8 | 14246.8 | 14117.6 | 14060.5 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.9 | 4.1 | 4.3 | 3.9 | 3.9 | 4.1 | 4.2 | 4.1 | 4.1 | 4.2 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 32.5 | 34.2 | 35.3 | 33.9 | 31.6 | 31.9 | 33.0 | 32.8 | 31.6 | 31.6 | 30.7 | 30.3 |
| វៀតណាម (ដុង) | 21138.2 | 21917.7 | 22507.5 | 22645.9 | 22749.5 | 22483.9 | 22675.7 | 22744.1 | 22902.9 | 23255.5 | 23258.3 | 23217.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.2 | 6.3 | 6.6 | 6.8 | 6.4 | 6.4 | 6.8 | 6.9 | 6.7 | 6.8 | 7.0 | 7.0 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1053.6 | 1131.9 | 1161.0 | 1130.5 | 1072.0 | 1079.0 | 1120.9 | 1127.7 | 1125.0 | 1165.4 | 1193.4 | 1174.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 30.3 | 31.8 | 32.3 | 30.4 | 29.3 | 29.8 | 30.7 | 30.8 | 30.8 | 31.1 | 31.2 | 30.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 105.9 | 121.0 | 108.8 | 112.1 | 108.4 | 109.1 | 111.4 | 112.8 | 110.1 | 109.9 | 107.3 | 108.7 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៤-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 192.9 | 169.8 | 159.2 | 154.5 | 163.7 | 173.3 | 157.9 | 162.8 | 167.5 | 175.9 | 170.1 | 166.8 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 821.4 | 622.7 | 643.6 | 714.7 | 673.7 | 601.0 | 612.0 | 554.8 | 586.9 | 568.1 | 570.1 | 680.2 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 1755.6 | 1392.7 | 1416.1 | 1688.3 | 1504.0 | 1433.3 | 1365.2 | 1303.1 | 1436.6 | 1549.5 | 1389.7 | 1410.1 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 434.9 | 395.5 | 406.7 | 452.3 | 459.3 | 451.0 | 424.7 | 426.7 | 426.7 | 430.0 | 439.7 | 442.7 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 491.8 | 390.4 | 405.7 | 400.6 | 418.3 | 435.6 | 390.6 | 368.9 | 353.3 | 347.8 | 339.7 | 347.3 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 96.2 | 49.6 | 40.7 | 52.6 | 64.7 | 71.9 | 74.2 | 67.2 | 63.0 | 65.1 | 59.7 | 60.3 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 65.6 | 41.0 | 35.2 | 42.4 | 47.9 | 53.3 | 54.1 | 42.9 | 40.9 | 49.4 | 46.0 | 43.3 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 71.5 | 41.7 | 34.8 | 42.9 | 51.0 | 55.6 | 56.6 | 52.2 | 49.5 | 51.1 | 48.9 | 49.4 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ការអនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុបកើន ២៩,៤% ធៀបនឹងកាលពីមួយឆ្នាំមុន (ឬកើន ១០៧,០% ធៀបនឹងត្រីមាសមុន) ដល់ ២.៣៨៧,៨ លានដុល្លារ ។ ក្នុងនេះ ការអនុម័តវិនិយោគក្នុងវិស័យឧស្សាហកម្ម កើន ១៨៣,០% ដែលជំរុញឡើងដោយសារ កំណើនការអនុម័តវិនិយោគផ្នែកសម្លៀកបំពាក់ ដល់ ៤០,៣%។ ក្នុងពេលជាមួយគ្នា ការអនុម័តវិនិយោគក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៣១,០% និង ក្នុងវិស័យសេវាកម្ម ធ្លាក់ចុះ ២,៧% ប៉ុន្តែការអនុម័តវិនិយោគផ្នែកសណ្ឋាគារនិងទេសចរណ៍ កើន ២៧,៧%។ បើធៀបនឹងត្រីមាសមុន ការអនុម័តវិនិយោគគិតជា ទ្រព្យសកម្មជាប់លាប់ កើនឡើងក្នុងគ្រប់វិស័យ ពោលគឺ ក្នុងវិស័យកសិកម្ម កើន ១.៣៣៩,៣% ក្នុងវិស័យឧស្សាហកម្ម កើន ២០៤,៦% និងក្នុងវិស័យសេវាកម្ម កើន ៦៩,៥%។

***ចំណូលសរុបរបស់រដ្ឋាភិបាល កើន ៨,៩% ដោយសារមានកំណើន ចំណូលចរន្ត (៨,៩%) ចំណូលពន្ធ (១១,០%) ចំណូលពន្ធក្នុងស្រុក (១២,៦%) ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស (១,៧%) ចំណូលមិនមែនពន្ធផ្សេងទៀត (៣៣,០%) និង ចំណូលជាមូលធន (៩,៦%) ប៉ុន្តែមានការធ្លាក់ចុះ: ចំណូលមិនមែនពន្ធ (៣,៨%) ចំណូលលើទ្រព្យសម្បត្តិ (២៤,២%) និង ចំណូលពន្ធលើការលក់ទំនិញនិងសេវា (៦,១%)***

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍អន្តរជាតិមកដល់កម្ពុជាសរុប ថយចុះ ១,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនដល់ ១.២៩៩.០៨២នាក់ ក្នុងនេះ ទេសចរមកពីចិន ថយចុះ ១៤,៩% មកពីកូរ៉េខាងត្បូង ថយចុះ ១៣,៥% ពីជប៉ុន ថយចុះ ១០,៧% ពីបារាំង ថយចុះ ១៣,៤% ពីម៉ាឡេស៊ី ថយចុះ ១,៨% ប៉ុន្តែទេសចរមកពីវៀតណាម កើន ២៥,៨% ពីថៃ កើន ២១,៤% ពីសហរដ្ឋអាមេរិក កើន ២,៤% និងពីអង់គ្លេស កើន ២,៦%។ បើធៀបនឹងត្រីមាសមុន ទេសចរអន្តរជាតិមកដល់កម្ពុជាសរុប កើន ២១,៧% ដោយសារកំណើនទេសចរមកពីប្រទេសភាគច្រើន ក្រៅតែទេសចរមកពីចិន ដែលបានថយចុះ ១៣,២%។

ធៀបនឹងកាលពីមួយឆ្នាំមុន ការនាំចេញសរុប កើន ១២,៤% ដល់ ៣.៥២៤,៩លានដុល្លារ ដែលជំរុញឡើងដោយសារកំណើនការនាំចេញ សម្លៀកបំពាក់ (៩,៩%) គ្រឿងអេឡិចត្រូនិក (៤៨,៦%) ផលិតផលកសិកម្មសរុប (៨,៥%) ផលិតផលកសិកម្មផ្សេងៗ (៩៧,៩%) និង ទំនិញផ្សេងៗ (៣០,០%)។ សម្រាប់ការនាំចេញសម្លៀកបំពាក់ ការនាំចេញទៅសហរដ្ឋអាមេរិក កើន ៣៥,២% ទៅអាស៊ាន កើន ២៩,៤% និងទៅប្រទេសផ្សេងៗ កើន ៧,១% ប៉ុន្តែការនាំចេញទៅសហភាពអឺរ៉ុប ធ្លាក់ចុះ ៦,២% និងទៅអង់គ្លេស ធ្លាក់ចុះ ០,៤%។ បើធៀបនឹងត្រីមាសមុន ការនាំចេញសរុប ធ្លាក់ចុះ ១៧,៣% ដោយសារការនាំចេញក្នុងគ្រប់វិស័យចម្បងៗបានធ្លាក់ចុះ លើកលែងតែក្នុងវិស័យកសិកម្ម។ ដោយឡែកការនាំចេញសម្លៀកបំពាក់ធ្លាក់ចុះ ១៩,៥% ក្នុងនេះ ការនាំចេញទៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ១៥,៧% ទៅសហភាពអឺរ៉ុប ធ្លាក់ចុះ ២៥,៨% ទៅជប៉ុន ធ្លាក់ចុះ ១៨,៧% ទៅអង់គ្លេស ធ្លាក់ចុះ ២៦,៦% និងទៅប្រទេសផ្សេងៗ ធ្លាក់ចុះ ១៤,៩% ប៉ុន្តែវាកើនឡើងបានមួយច្រក គឺទៅអាស៊ាន ដែលកើន ១០,២%។ ការនាំចេញផ្នែកកសិកម្ម កើន ៣៦,៦% ដែលជំរុញឡើងដោយសារកំណើនការនាំចេញ កៅស៊ូ (២២,១%) ឈើ (១២,១%) ត្រី (៣៧,៥%) អង្ករ (៦៦,១%) និងផលិតផលកសិកម្មផ្សេងៗ (១១,៧%)។

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ការនាំចូលសរុបកើន ២៧,១% ដោយសារ កំណើនការនាំចូល សាំង (១៣,១%) ម៉ាស៊ូត (១៦,៨%) សម្ភារសំណង់ (៣៨,១%) និង ទំនិញផ្សេងៗ (២៧,៧%)។ បើធៀបនឹងត្រីមាសមុន ការនាំចូលសរុប កើន ៤,៦% ដោយសារកំណើនការនាំចូល សាំង (២,៨%) ម៉ាស៊ូត (៤៩,៦%) និង ទំនិញផ្សេងៗ (៤,៤%) ប៉ុន្តែការនាំចូលសម្ភារសំណង់ ធ្លាក់ចុះ ១៧,៣%។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ២៣,០% ធៀបនឹងកាលពីមួយឆ្នាំមុន ដោយសារកំណើន ចំណូលចរន្ត (២៣,៩%) ចំណូលពន្ធ (៣០,៧%) ចំណូលពន្ធក្នុងស្រុក (៣៣,៦%) ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស (១៤,២%) និង ចំណូលមិនមែនពន្ធផ្សេងទៀត (៨,២%) ប៉ុន្តែមានការធ្លាក់ចុះ: ចំណូលមិនមែនពន្ធ (៨,១%) ចំណូលលើទ្រព្យសម្បត្តិ (៥០,៦%) ចំណូលលើការលក់ទំនិញនិងសេវា (៨,៣%) និង ចំណូលជាមូលធន (៣៣,៤%)។ បើធៀបនឹងត្រីមាសមុន ចំណូលសរុបរបស់រដ្ឋាភិបាល កើន ៨,៩% ដោយសារមានកំណើន ចំណូលចរន្ត (៨,៩%) ចំណូលពន្ធ (១១,០%) ចំណូលពន្ធក្នុងស្រុក (១២,៦%) ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស (១,៧%) ចំណូលមិនមែនពន្ធផ្សេងទៀត (៣៣,០%) និង ចំណូលជាមូលធន (៩,៦%) ប៉ុន្តែមានការធ្លាក់ចុះ: ចំណូលមិនមែនពន្ធ (៣,៨%) ចំណូលលើ

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និង ពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

ទ្រព្យសម្បត្តិ (២៤,២%) និង ចំណូលពន្ធលើការលក់ទំនិញនិងសេវា (៦,១%)។

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ចំណាយសរុប កើន ៥៧,៤% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ៧.៦៧៦,៨ប៊ីលានរៀល ដោយសារមានកំណើន ចំណាយជាមូលធន (១២៤,៨%) ចំណាយចរន្ត (២៩,៧%) ចំណាយលើបៀវត្សរ៍ (៨,៣%) ចំណាយលើឧបត្ថម្ភធននិងជំនួយសង្គម (៩៨,៣%) និងចំណាយចរន្តផ្សេងទៀត (៥១,៣%)។ បើធៀបនឹងត្រីមាសមុន ចំណាយសរុប កើន ៤២,៥% ដែលជំរុញឡើងដោយសារចំណាយគ្រប់ប្រភេទបានកើនឡើង លើកលែងតែចំណាយលើបៀវត្សរ៍ដែលថយចុះ ១០,៤%។

សមតុល្យសរុប មានឱនភាព ៧៤៦,៥ប៊ីលានរៀល ពោលគឺមានកំណើនអវិជ្ជមាន ១៩៨,៤% ធៀបនឹងឱនភាពសរុបនៅត្រីមាសដូចគ្នាឆ្នាំមុន ឬ កំណើនអវិជ្ជមាន ១៧៦,៣% ធៀបនឹងត្រីមាសមុន។ គួរកត់សំគាល់ថា ឱនភាពនៅត្រីមាសទី៤ ឆ្នាំ២០១៩ នេះ មានដំណើរស្រដៀងគ្នានឹងឱនភាពនៅត្រីមាសទី៣ ឆ្នាំ២០១៨ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប (CPI) នៅភ្នំពេញមានកម្រិត ២,០% ឬ ០,៤ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែ ០,២ឯកតាភាគរយ ខ្ពស់ជាងត្រីមាសមុន។ សន្ទស្សន៍ថ្លៃស្បៀងអាហារនិងភេសជ្ជៈមិនមែនស្រា មានកម្រិត ០,៣ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែ ០,៦ឯកតាភាគរយ ខ្ពស់ជាងត្រីមាសមុន។ សន្ទស្សន៍ថ្លៃដឹកជញ្ជូន មានកម្រិត -២,៥% ឬ ៣,៩ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន និង ០,១ឯកតាភាគរយ ទាបជាងត្រីមាសមុន។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៦៣,៧រៀល/ដុល្លារ និងឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៦រៀល/១០០ដុង ប៉ុន្តែចុះថ្លៃ ០,៩% ទល់នឹងប្រាក់បាតថៃ ដល់ ១៣៤,៩រៀល/បាត។ មាសឡើងថ្លៃ ១,៤% ដល់ ១៧៨,១ដុល្លារ/ជី។ ម៉ាស៊ូតឡើងថ្លៃ ៥,៣% ដល់ ៣.៦៨៥,៩រៀល/លីត្រ ប៉ុន្តែសាំងចុះថ្លៃ ៣,៦% ដល់ ៣.៤៩៩,៥រៀល/លីត្រ។

## ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

ផ្នែកនេះ ពិពណ៌នាដោយសង្ខេបពីស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយផ្អែកតាមអង្កេតលើពលករ ៤៨០នាក់ (១២០នាក់ ជាកម្មកររោងចក្រកាត់ដេរ) នៅខែកុម្ភៈ ២០១៩។ លទ្ធផលអង្កេតបង្ហាញថា បើធៀបនឹងខែដូចគ្នាឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃបានថយចុះសម្រាប់ពលករ ២ប្រភេទ ពោលគឺ អ្នករត់ស៊ីក្លូ និង អ្នកលក់បន្លែតូចតាច រីឯពលករ ៨ប្រភេទទៀតបានកើនប្រាក់ចំណូល។

ធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករត់ស៊ីក្លូ ថយចុះ ៦,៥% ដល់ ១០.៩៩៧រៀល និងរបស់ អ្នកលក់បន្លែតូចតាច ថយចុះ ១៩,៦% ដល់ ១៥.២០៧រៀល ប៉ុន្តែប្រាក់ចំណូលប្រចាំថ្ងៃរបស់ អ្នកលីសែង កើន ១៤,៩% របស់អ្នករើសអេតចាយ កើន ១៤,០% របស់អ្នករត់តុភោជនីយដ្ឋាន កើន ៤,៩% របស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ១១,៥% របស់កម្មកររោងចក្រកាត់ដេរ កើន ២,៦% របស់អ្នករត់ម៉ូតូឌុប កើន ២០,៧% របស់កម្មករសំណង់គ្មានជំនាញ កើន ១៥,៦% និងរបស់កម្មករសំណង់មានជំនាញ កើន ៣,៤%។

កម្មករសំណង់មានជំនាញ មានប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមខ្ពស់ជាងគេ ដោយទទួលបានដល់ ២៧.១៦៤រៀល បន្ទាប់មកគឺ កម្មករសំណង់គ្មានជំនាញ (២២.៩១៦រៀល) រីឯអ្នកស៊ីឈ្នួលធ្វើស្រែ មានប្រាក់ចំណូលប្រចាំថ្ងៃទាបជាងគេ ត្រឹម ៨.៧០៦រៀល បន្ទាប់មកគឺ អ្នករត់តុភោជនីយដ្ឋាន ដែលបានត្រឹម ៩.១៥៤រៀល។

ក្នុងចំណោមពលករ ៩ប្រភេទ មានសរុប ៣៦០នាក់ (គឺក្រៅពីកម្មកររោងចក្រកាត់ដេរ) ភាគច្រើន (៨១,៦%) មកពីគ្រួសារធំៗមានសមាជិកពី ៤ ដល់ ៨នាក់។ ម្យ៉ាងទៀត មានតែពលករ ១៤,៤% ប៉ុណ្ណោះដែលរាយការណ៍ថា គាត់មិនមែនជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ពលករភាគច្រើន (៦៩,៤%) ធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប រីឯអ្នកឯទៀតធ្វើចំណាកស្រុកមកជាមួយគ្រួសារគាត់។ មានពលករជិតពាក់កណ្តាល (៤៩,៤%) រាយការណ៍ថា គាត់គ្មានធ្វើការអ្វីទៀតក្រៅពីការងារសព្វថ្ងៃនេះទេ និងមាន ៤៦,៩% ប្រាប់ថាគាត់មានធ្វើការនៅផ្ទះ ដូចជា ការងារដាំដុះ ចិញ្ចឹមសត្វ ឬធ្វើជាបុគ្គលិករដ្ឋ ហើយក្រៅពីនោះ មានការងារបន្ថែម ដូចជា លក់ពលកម្មនៅក្នុងភូមិ (០,៦%) លក់ពលកម្មនៅក្រៅភូមិ (១,៤%) ប្រមូលនិងលក់ធនធានទ្រព្យរួមក្នុងមូលដ្ឋាន (០,៣% (ឧ. ក្រងស្លឹក)) ឬ លក់ដូរបន្តិចបន្តួច (០,៨៣%)។ តបនឹងសំណួរថា តើប្រាក់ចំណូលរបស់អ្នកអាចផ្គត់ផ្គង់គ្រួសារបានឬទេ? ពលករភាគច្រើន (៩១,៤%) ឆ្លើយថា បានមួយភាគ ពលករ ៦,៩% ឆ្លើយថាផ្គត់ផ្គង់បាន និង ១,៧% ថា មិនបានទេ។ ពលករគ្រប់គ្នាបានលើកនូវក្តីបារម្ភពីការឡើងថ្លៃស្បៀងអាហារ ដែលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពគាត់ ព្រោះប្រាក់ចំណូលរបស់គាត់ត្រូវយកទៅចំណាយជាសំខាន់លើស្បៀងអាហារ (៩៨,៤%)។

សម្រាប់កម្មករកាត់ដេរ ១២០នាក់ក្នុងអង្កេតនេះ ភាគច្រើន (៧២,៥%) មកពីគ្រួសារធំៗមានសមាជិកពី ៤ ដល់ ៦នាក់។ ពួកគាត់រាយការណ៍ថា ប្រាក់ចំណូលប្រចាំខែរបស់គាត់យកទៅចំណាយជាសំខាន់លើ ស្បៀងអាហារ (៦៨,៧%) កន្លែងស្នាក់នៅ (១៩,៧%) ការថែទាំសុខភាព (០,២%) និងចំណាយផ្សេងៗទៀត (១១,៧%)។ តបនឹងសំណួរថា តើអ្នកចង់នៅធ្វើការរោងចក្រយូរឆ្នាំឬយ៉ាងណា? កម្មករ ៥៥,០% ឆ្លើយថា មិនដឹង ៣៩,៥% ឆ្លើយថា មិនចង់ទេ ហើយក្រៅពីនោះ (១២,៥%) ថាចង់នៅយូរឆ្នាំ។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៤-១៩

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 56.5 | 169.8 | 117.1 | 62.9 | 99.5 | 30.4 | 45.2 | 39.8 | 17.2 | 48.2 | 1.9 | 27.5 |
| ឧស្សាហកម្ម | 1002.5 | 1014.7 | 1436.4 | 982.2 | 259.6 | 193.4 | 408.2 | 325.0 | 292.9 | 113.7 | 302.0 | 919.9 |
| *. សម្លៀកបំពាក់* | 393.5 | 225.2 | 380.7 | 211.1 | 53.2 | 31.4 | 49.9 | 52.8 | 73.9 | 34.4 | 47.3 | 74.1 |
| សេវាកម្ម | 622.6 | 2734.4 | 1664.3 | 3858.6 | 110.2 | 2156.2 | 605.5 | 1479.8 | 1625.6 | 2518.2 | 849.7 | 1440.4 |
| *. សណ្ឋាគារ និងទេសចរណ៍* | 446.9 | 98.6 | 1366.9 | 2759.6 | 75.2 | 106.6 | 68.3 | 1333.9 | 1618.8 | 2518.2 | 808.7 | 1703.8 |
| សរុប | 1583.9 | 3918.9 | 3217.7 | 4903.7 | 469.3 | 2380.0 | 1058.9 | 1844.7 | 1935.6 | 2680.1 | 1153.5 | 2387.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 310.5 | 407.2 | -55.5 | 74.2 | 4.9 | 38.5 | -57.0 | 107.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -63.4 | 147.4 | -17.9 | 52.4 | 257.2 | 44.0 | -64.8 | 1513.7 | 312.5 | 12.6 | 8.9 | 29.4 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៤-១៩

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 560.3 | 694.7 | 830.0 | 1210.8 | 505.9 | 425.8 | 509.0 | 583.7 | 683.4 | 609.1 | 572.5 | 496.9 |
| វៀតណាម | 905.8 | 987.8 | 959.7 | 835.4 | 186.8 | 199.9 | 197.7 | 215.9 | 186.9 | 214.8 | 235.7 | 271.5 |
| កូរ៉េខាងត្បូង | 424.4 | 395.3 | 357.2 | 345.0 | 126.1 | 48.5 | 483.9 | 78.8 | 95.7 | 43.6 | 47.4 | 68.1 |
| ថៃ | 279.5 | 349.9 | 398.1 | 394.9 | 83.7 | 76.1 | 75.5 | 147.0 | 97.9 | 76.3 | 113.9 | 178.4 |
| សហរដ្ឋអាមេរិក | 191.4 | 217.5 | 238.7 | 256.5 | 79.1 | 54.6 | 47.7 | 69.5 | 79.0 | 53.2 | 45.5 | 71.2 |
| ជប៉ុន | 215.8 | 193.3 | 191.6 | 203.4 | 59.0 | 38.7 | 47.7 | 65.1 | 60.2 | 40.4 | 48.9 | 58.2 |
| បារាំង | 141.1 | 145.7 | 150.3 | 166.4 | 56.6 | 29.4 | 33.5 | 51.4 | 59.4 | 27.3 | 32.9 | 44.5 |
| ចក្រភពអង់គ្លេស | 133.3 | 154.3 | 159.5 | 171.2 | 51.2 | 33.7 | 33.0 | 44.5 | 59.4 | 29.7 | 28.5 | 45.6 |
| ម៉ាឡេស៊ី | 144.4 | 149.4 | 152.8 | 179.3 | 44.8 | 41.0 | 49.4 | 65.8 | 48.7 | 43.2 | 46.5 | 64.6 |
| តាមផ្លូវអាកាស | 2273.5 | 2476.0 | 2778.0 | 3312.7 | 1157.6 | 846.5 | 954.8 | 1137.9 | 1299.1 | 1054.8 | 1039.9 | 1010.2 |
| តាមផ្លូវគោក និងទឹក | 2229.3 | 2299.2 | 2331.4 | 2289.4 | 553.6 | 443.9 | 419.6 | 687.1 | 578.7 | 405.8 | 436.0 | 786.1 |
| សរុប | 4502.8 | 4775.2 | 4980.4 | 5602.2 | 1711.3 | 1290.4 | 1374.4 | 1825.0 | 1877.9 | 1460.6 | 1475.8 | 1796.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 1.3 | -24.6 | 6.5 | 32.8 | 2.9 | -22.2 | 1.0 | 21.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 7.0 | 6.1 | 4.3 | 12.5 | 129.3 | -158.8 | 9.9 | 8.0 | 9.7 | 13.2 | 7.4 | -1.6 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៤-១៩ *

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 8106.0 | 9256.4 | 10043.3 | 10772.9 | 2834.6 | 3000.2 | 3813.7 | 3135.4 | 3222.7 | 3379.0 | 4263.9 | 3524.9 |
| សម្លៀកបំពាក់ | 5960.5 | 6827.0 | 7308.0 | 8020.3 | 2092.1 | 2240.6 | 2871.0 | 2302.3 | 2463.4 | 2526.3 | 3143.8 | 2530.9 |
| *- សហរដ្ឋអាមេរិក* | 1963.6 | 2009.4 | 1831.5 | 1923.8 | 538.4 | 573.9 | 743.5 | 627.4 | 739.8 | 802.9 | 1006.5 | 848.0 |
| *- សហភាពអឺរ៉ុប* | 2403.7 | 2903.9 | 2928.7 | 2782.2 | 670.1 | 805.2 | 916.7 | 763.4 | 719.2 | 801.1 | 965.4 | 716.2 |
| *- អាស៊ាន* | 83.3 | 103.4 | 98.4 | 106.9 | 28.6 | 32.7 | 33.0 | 41.1 | 38.1 | 41.3 | 48.2 | 53.1 |
| *- ជប៉ុន* | 383.1 | 524.2 | 655.5 | 701.2 | 224.7 | 165.2 | 276.6 | 224.3 | 262.9 | 175.8 | 291.2 | 236.8 |
| *- ចក្រភពអង់គ្លេស* | - | - | 439.8 | 904.0 | 219.5 | 203.9 | 382.5 | 201.1 | 211.5 | 197.7 | 272.9 | 200.3 |
| *- ប្រទេសផ្សេងៗ* | 1126.8 | 1286.3 | 1354.2 | 1602.2 | 410.9 | 459.7 | 518.8 | 445.0 | 491.7 | 507.5 | 559.7 | 476.4 |
| គ្រឿងអេឡិចត្រូនិក | - | - | - | 380.0 | 76.2 | 90.9 | 83.4 | 78.3 | 71.9 | 123.8 | 142.3 | 116.3 |
| គ្រឿងយានយន្ត | - | - | - | 11.6 | 11.9 | 13.1 | 15.3 | 54.1 | 20.4 | 18.2 | 22.7 | 24.1 |
| កសិកម្ម | 624.4 | 548.8 | 534.1 | 706.4 | 205.9 | 166.0 | 213.6 | 265.5 | 210.4 | 177.7 | 211.0 | 288.1 |
| *- កៅស៊ូ* | 153.9 | 165.4 | 165.3 | 273.5 | 52.4 | 36.5 | 59.7 | 69.1 | 43.8 | 42.2 | 60.0 | 73.3 |
| *- ឈើ* | 132.0 | 46.3 | 47.2 | 100.5 | 30.0 | 34.0 | 42.0 | 36.3 | 22.2 | 35.2 | 42.4 | 47.5 |
| *- ត្រី* | 0.8 | 0.5 | 0.6 | 0.6 | 1.0 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| *- អង្ករ* | 248.5 | 315.3 | 300.8 | 255.1 | 106.7 | 71.8 | 88.7 | 146.4 | 122.4 | 72.2 | 84.5 | 140.2 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 89.1 | 21.3 | 20.2 | 76.7 | 15.8 | 23.6 | 23.2 | 13.6 | 21.9 | 28.1 | 24.1 | 26.9 |
| ផ្សេងៗ | 1520.1 | 1880.2 | 2201.2 | 1654.7 | 448.6 | 489.6 | 630.4 | 435.2 | 456.6 | 532.9 | 744.0 | 565.6 |
| ការនាំចូលសរុប | 10295.4 | 11494.5 | 15013.4 | 16815.4 | 4244.5 | 4496.0 | 3976.5 | 4187.6 | 4437.7 | 5328.6 | 5091.4 | 5324.3 |
| សាំង | 334.7 | 377.3 | 384.8 | 256.7 | 64.9 | 60.8 | 87.0 | 107.8 | 121.1 | 117.1 | 118.6 | 121.9 |
| ម៉ាស៊ូត | 602.3 | 607.8 | 709.1 | 472.9 | 102.0 | 116.9 | 162.0 | 213.2 | 228.2 | 250.2 | 166.4 | 248.9 |
| សម្ភារសំណង់ | 117.6 | 164.4 | 253.2 | 304.3 | 100.7 | 138.7 | 162.7 | 162.5 | 170.8 | 231.4 | 271.2 | 224.4 |
| ផ្សេងៗ | 9240.7 | 10345.1 | 13666.3 | 15781.6 | 3976.9 | 4179.7 | 3564.8 | 3704.2 | 3917.7 | 4729.9 | 4535.2 | 4729.1 |
| ជញ្ជីងពាណិជ្ជកម្ម | -2184.3 | -2238.1 | -4970.0 | -5974.1 | -1409.9 | -1495.9 | -162.8 | -1052.3 | -1215.0 | -1990.6 | -827.5 | -1799.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | | 4.6 | 7.1 | 28.1 | -19.8 | 7.0 | 2.6 | 24.4 | -19.5 |
| ការនាំចេញសរុប | - | - | - | | 0.3 | 5.8 | 27.1 | -17.8 | 2.8 | 7.8 | 26.2 | -17.3 |
| ការនាំចូលសរុប | - | - | - | | 24.0 | 5.9 | -11.6 | 5.3 | 6.0 | 27.2 | -4.5 | 4.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 10.7 | 14.5 | 7.0 | 9.7 | 12.7 | 19.6 | 25.4 | 15.1 | 17.7 | 12.8 | 9.5 | 9.9 |
| ការនាំចេញសរុប | 16.1 | 14.2 | 8.5 | 7.9 | 23.7 | 14.2 | 23.1 | 11.0 | 13.7 | 12.6 | 11.8 | 12.4 |
| ការនាំចូលសរុប | 19.7 | 11.7 | 30.6 | 12.0 | 33.8 | -24.0 | -7.6 | 22.3 | 4.6 | 18.5 | 28.0 | 27.1 |

Note: Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៤-១៩ (ប៊ីលានរៀល)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 10543.4 | 11879.9 | 14201.5 | 16582.0 | 4357.6 | 5080.6 | 4670.3 | 5634.6 | 5097.5 | 6357.1 | 6364.5 | 6930.3 |
| ចំណូលចរន្ត | 10359.4 | 11759.0 | 14088.7 | 16481.4 | 4344.8 | 5035.2 | 4625.6 | 5543.5 | 5066.8 | 6322.2 | 6309.2 | 6869.7 |
| ចំណូលពន្ធ | 8995.2 | 10502.4 | 12196.5 | 14314.3 | 3984.9 | 4425.4 | 4010.2 | 4598.7 | 4524.3 | 5663.5 | 5415.1 | 6009.8 |
| ពន្ធក្នុងស្រុក | 7226.5 | 8591.7 | 10185.8 | 12338.7 | 3469.8 | 3850.4 | 3424.9 | 3903.2 | 3904.9 | 4944.9 | 4634.1 | 5215.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1822.7 | 1910.7 | 2010.7 | 1875.6 | 515.2 | 575.0 | 585.2 | 695.4 | 619.4 | 718.6 | 781.0 | 793.9 |
| ចំណូលមិនមែនពន្ធ | 1310.3 | 1256.6 | 1892.2 | 2167.2 | 359.8 | 609.8 | 615.4 | 935.8 | 542.5 | 658.7 | 894.1 | 859.9 |
| ចំណូលលើទ្រព្យសម្បត្តិ | 88.5 | 77.3 | 116.0 | 127.2 | 7.7 | 130.5 | 12.6 | 46.4 | 177.4 | 34.0 | 30.2 | 22.9 |
| លក់ទំនិញ និងសេវា | 871.2 | 1047.1 | 1248.3 | 1517.0 | 341.0 | 388.9 | 527.8 | 817.9 | 330.7 | 531.2 | 798.5 | 750.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 350.5 | 132.2 | 528.0 | 523.1 | 11.1 | 87.4 | 75.0 | 80.5 | 34.5 | 93.5 | 65.5 | 87.1 |
| ចំណូលជាមូលធន | 184.0 | 121.0 | 113.4 | 100.5 | 12.9 | 45.4 | 44.7 | 91.1 | 30.7 | 35.0 | 55.4 | 60.7 |
| ចំណាយសរុប | 13306.5 | 13849.5 | 13775.4 | 17251.0 | 3583.2 | 4706.2 | 5861.4 | 4876.3 | 4150.4 | 4997.6 | 5386.5 | 7676.8 |
| ចំណាយជាមូលធន | 5590.7 | 5290.3 | 3785.3 | 5207.2 | 812.9 | 1517.8 | 1978.3 | 1421.2 | 1025.0 | 1392.7 | 1358.6 | 3195.4 |
| ចំណាយចរន្ត | 7715.8 | 8544.6 | 9990.1 | 12043.7 | 2770.3 | 3188.5 | 3883.1 | 3455.1 | 3125.4 | 3604.9 | 4027.9 | 4481.3 |
| បៀវត្សរ៍ | 3755.5 | 4271.9 | 5381.7 | 6647.4 | 1760.3 | 1911.1 | 2148.8 | 1738.3 | 1820.2 | 1911.1 | 2102.0 | 1883.3 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1627.0 | 1742.9 | 1774.9 | 2314.8 | 469.9 | 621.1 | 597.2 | 817.2 | 729.2 | 1061.9 | 855.5 | 1620.3 |
| ចំណាយចរន្តផ្សេងទៀត | 2333.4 | 2529.8 | 2833.5 | 5394.3 | 1010.0 | 1277.4 | 1734.4 | 1716.9 | 1305.2 | 1693.8 | 1925.8 | 2598.1 |
| សមតុល្យជាទូទៅ | -2763.1 | -1969.6 | 426.1 | -669.1 | 774.5 | 374.4 | -1191.1 | 758.3 | 947.1 | 1359.6 | 978.0 | -746.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 3972.1 | 3729.4 | 1878.9 | 3358.1 | 401.6 | 1064.4 | 413.1 | 634.4 | 652.8 | 895.5 | 608.8 | 1383.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -1428.7 | -2034.9 | -1858.7 | -2454.1 | 101.7 | 90.5 | -36.3 | 66.7 | -44.4 | -7.6 | 11.9 | -18.0 |

Source: Ministry of Economy and Finance website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៤-១៩

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.9 | 1.2 | 3.1 | 2.9 | 2.3 | 2.7 | 2.5 | 2.4 | 1.9 | 1.9 | 1.8 | 2.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 4.9 | 4.0 | 5.6 | 3.4 | 1.9 | 2.9 | 2.5 | 2.5 | 2.1 | 2.1 | 1.6 | 2.2 |
| - ដឹកជញ្ជូន | -1.0 | -9.2 | -6.9 | 4.1 | 3.1 | 3.9 | 3.3 | 1.4 | -3.8 | -3.8 | -1.5 | -2.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4036.2 | 4060.4 | 4053.7 | 4047.5 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 | 4063.7 |
| រៀលក្នុង ១ បាតថៃ | 124.9 | 119.4 | 115.5 | 120.0 | 127.7 | 127.4 | 124.2 | 124.2 | 127.4 | 128.9 | 133.7 | 134.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.1 | 18.7 | 18.2 | 17.9 | 17.8 | 17.9 | 17.7 | 17.5 | 17.4 | 17.5 | 17.7 | 17.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 152.3 | 140.6 | 151.2 | 151.5 | 160.3 | 157.6 | 146.1 | 147.3 | 156.6 | 157.1 | 175.7 | 178.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4852.1 | 3771.3 | 3004.0 | 3385.8 | 3679 | 3915.7 | 3784.3 | 3856.3 | 3413.9 | 3595.4 | 3499.7 | 3685.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 5083.3 | 3951.7 | 3336.8 | 3716.0 | 3914 | 4120.3 | 4003.0 | 3893.0 | 3405.7 | 3770.2 | 3629.3 | 3499.5 |

Sources: NIS, NBC; CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៣-១៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 21260.1 | 26699.7 | 26665.5 | 31814.5 | 42575.3 | 46707.0 | 49421.9 | 52669.4 | 55214.3 | 58148.8 | 62699.5 | 67081.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 11508.3 | 15859.8 | 22157.6 | 25802.3 | 28743.5 | 28457.0 | 29926.1 | 31941.8 | 33228.9 | 33997.2 | 33548.0 | 34814.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2794.9 | -4359.1 | -6428.8 | -8148.5 | -11066.5 | -12381.1 | -12887.7 | -12996.4 | -14803.7 | -17381.0 | -18747.4 | -20263.2 |
| ឥណទានដល់វិស័យឯកជន | 27608.8 | 36244.6 | 46071 | 56458.8 | 66922.6 | 68686.5 | 72464.2 | 77925.6 | 82419.3 | 86574.4 | 91568.6 | 98320.3 |
| រូបិយវត្ថុទូទៅ | 32768.4 | 42559.5 | 48823.1 | 57616.6 | 71318.9 | 75164.0 | 79348.0 | 84611.3 | 88443.2 | 92146.0 | 96247.6 | 101895.8 |
| រូបិយវត្ថុ | 4878.2 | 6308.4 | 6741.4 | 7273.0 | 9428.4 | 9578.5 | 9553.9 | 10146.0 | 10226.8 | 10782.0 | 11274.5 | 13465.9 |
| រូបិយវត្ថុផ្សេងៗ | 21260.1 | 26699.7 | 42081.7 | 50343.8 | 61890.4 | 65585.5 | 69794.1 | 74465.2 | 78216.4 | 81364.0 | 84973.0 | 88429.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 14.6 | 29.9 | 14.7 | 18.0 | 23.8 | 24.1 | 21.6 | 21.3 | 24.0 | 22.6 | 21.3 | 20.4 |
| រូបិយវត្ថុ | 20.6 | 29.3 | 6.9 | 7.9 | 29.6 | 27.3 | 16.7 | 13.7 | 8.5 | 12.6 | 18.0 | 32.7 |
| រូបិយវត្ថុផ្សេងៗ | 13.6 | 30.0 | 16.1 | 19.6 | 22.9 | 23.7 | 22.3 | 22.4 | 26.4 | 24.1 | 21.7 | 18.8 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | 2019 | | 2020 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នករត់ស៊ីក្លូ | 11667 | 11516 | 10793 | 10793 | 11764 | 10567 | 11114 | 12046 | 10997 | 8.2 | 14.7 | -6.5 |
| អ្នកលីសែង | 14628 | 14318 | 14942 | 14942 | 15882 | 17323 | 16560 | 18802 | 18246 | 4.2 | 21.7 | 14.9 |
| អ្នកលក់បន្លែតូចតាច | 15125 | 17177 | 17015 | 17015 | 18912 | 21472 | 19197 | 18651 | 15207 | -4.7 | -11.3 | -19.6 |
| អ្នករើសអេតចាយ | 11574 | 10299 | 11591 | 11591 | 12941 | 12685 | 13123 | 13099 | 14759 | -1.2 | 4.2 | 14 |
| អ្នករត់តុភោជនីយដ្ឋាន* | 17772 | 20008 | 22901 | 22901 | 8299 | 8348 | 8564 | 8724 | 8706 | 7.8 | 4.5 | 4.9 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 14542 | 17365 | 17341 | 17341 | 8209 | 7909 | 9180 | 9376 | 9154 | 8.9 | 4.4 | 11.5 |
| កម្មកររោងចក្រកាត់ដេរ | 13847 | 14509 | 14231 | 14231 | 16073 | 15166 | 16076 | 16578 | 16483 | 5.0 | 5.1 | 2.6 |
| អ្នករត់ម៉ូតូឌុប | 7,914 | 7989 | 8093 | 8093 | 14705 | 15104 | 14219 | 14904 | 17748 | -7.0 | 1.8 | 20.7 |
| កម្មករសំណង់គ្មានជំនាញ | 8418 | 8088 | 8055 | 8055 | 19820 | 17987 | 18322 | 18814 | 22916 | 4.5 | -0.5 | 15.6 |
| កម្មករសំណង់មានជំនាញ | 14404 | 13688 | 14093 | 14093 | 26265 | 24743 | 25235 | 27225 | 27164 | 8.4 | 2.4 | 3.4 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI

តពីទំព័រ ២៤ **ព័ត៌មានថ្មីៗ...**

កសិកម្មរវាងប្រទេសចិន និងបណ្ដាប្រទេសនៅតំបន់មេគង្គឡានឆាង៖ ការវិភាគខ្សែសង្វាក់តម្លៃ ។ មូលនិធិទទួលបានពីកម្មវិធីស្វីស សម្រាប់ការស្រាវជ្រាវពីបញ្ហាសកលសម្រាប់ការអភិវឌ្ឍ (r4d) បានជួយទ្រទ្រង់ដល់ការអនុវត្តគម្រោង ស្ដីពី ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដល់កំណើន និងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគលើកត្តាសំខាន់ៗនៅកម្ពុជាតាំងពីឆ្នាំ២០១៧។ ផ្នែកនេះ ក៏កំពុងបន្តការស្រាវជ្រាវលើ ១.៥០០គ្រួសារ នៅតំបន់ជុំវិញបឹងទន្លេសាប សម្រាប់គម្រោង ស្ដីពី ការចងចាំសំខាន់ៗ (on the Salience of Memories) ដែលទទួលបានជំនួយគាំទ្រពី Ludwig-Maximilian's University of Munich ដោយគ្រោងអនុវត្តឲ្យបានរួចរាល់នៅខែមេសា។ នៅខែមីនា ផ្នែកនេះបានទទួលបន្ទុកលើអង្កេតបន្តបន្ទាប់បីដងក្នុងមួយឆ្នាំ សម្រាប់គម្រោង ស្ដីពី កសិកម្ម ការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រ។ អង្កេតវាយតម្លៃជំនាញផ្នែកឌីជីថល គឺជាគម្រោងថ្មីមួយដោយរួមសហការជាមួយ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT) ក្នុងក្របខ័ណ្ឌនៃ មូលនិធិសម្រាប់ការស្រាវជ្រាវកសាងសមត្ថភាព និងអភិវឌ្ឍន៍ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ផ្នែកសេដ្ឋកិច្ច បានចូលរួមក្នុងវេទិកាសាធារណៈ ស្ដីពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកា រៀបចំឡើងដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលពិនិត្យលើ សេដ្ឋកិច្ចម៉ាក្រូដោយមានការព្យាករណ៍សម្រាប់ឆ្នាំ២០២០ និងលើគោលនយោបាយ និងច្បាប់ថ្មីៗមួយចំនួន។ ផ្នែកនេះក៏បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលអំពី ចំណេះដឹងពីទិន្នន័យ ដែលធ្វើឡើងដោយ អង្គការទិន្នន័យអំពីការអភិវឌ្ឍ នៅក្រុងភ្នំពេញ និងសៀមរាប។

## មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ

នៅខែមករា វិទ្យាស្ថាន CDRI បានបោះពុម្ពផ្សាយឯកសារពិភាក្សា ស្ដីពី អ្នកសិក្សាអប់រំនៅកម្ពុជា៖ អត្តសញ្ញាណ និងតួនាទី។ ការសិក្សាបែបគុណវិស័យនេះ ផ្ដល់មូលនិធិដោយក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈមូលនិធិអាស៊ី (TAF) ដើម្បីស្រាវជ្រាវពីទិដ្ឋភាពសំខាន់ៗបួន ក្នុងនោះមានទាំង ការកសាងអត្តសញ្ញាណនៃអ្នកសិក្សាអប់រំនៅកម្ពុជា ក្នុងទម្រង់នៃ វិន័យ មុខងារ និងសង្គម។ ឯកសារពិភាក្សាពីរទៀត ស្ដីពី លក្ខណៈសំគាល់ និងបញ្ហាផ្សេងៗនៃការហាត់ការនៅតាមសហគ្រាសឯកជននៅកម្ពុជា ដែលទទួលជំនួយគាំទ្រពី DFAT ដែរ និង ការស្វែងយល់ពីទស្សនៈ និងវិធីសាស្ត្ររបស់ព្រឹទ្ធបុរសកម្ពុជាលើគណនេយ្យភាពនៃសាកលវិទ្យាល័យ ដែលទទួលជំនួយគាំទ្រពី ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ (SDC) កំពុងដាក់ជូនអ្នកកែសម្រួលអត្ថបទពិនិត្យ ហើយគ្រោងចេញផ្សាយនៅខែឧសភា។ ម៉្យាងទៀត DFAT បានជួយគាំទ្រការសិក្សាស្រាវជ្រាវបី គឺមាន សេដ្ឋកិច្ចនៃជម្រើសជំនាញឯកទេសក្នុងស្ទិម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យាៈ STEM), ការវាស់វែងអន្តរជាតូបនីយកម្មនៃឧត្តមសិក្សានៅកម្ពុជា, និង ប្រព័ន្ធបែងចែកប្រភេទឧត្តមសិក្សានៅកម្ពុជា។

ការសិក្សាស្រាវជ្រាវពីរ ផ្ដល់មូលនិធិដោយ SDC ពោលគឺ ការអភិវឌ្ឍ និងអនុវត្តការអប់រំនិងបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាពនៅក្នុង ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) នៅកម្ពុជា៖ គំនិត និងបទពិសោធន៍បានពីអ្នកពាក់ព័ន្ធបីប្រភេទ ហើយនិង ការអប់រំ និងការបណ្ដុះបណ្ដាលបែបកូនកាត់៖ លទ្ធភាព និងការអនុវត្ត បានបញ្ចប់ដំណាក់កាលប្រមូលទិន្នន័យ និងសរសេររបាយការណ៍។ លទ្ធផលរកឃើញ គ្រោងបោះពុម្ពផ្សាយជាឯកសារពិភាក្សា របស់ CDRI នៅពាក់កណ្ដាលខែមិថុនា ហើយការសិក្សាទាំងពីរនេះ មានពិនិត្យលំអិតពីស្ថានភាពបច្ចុប្បន្ននៃ TVET នៅកម្ពុជា។

ពីថ្ងៃទី ២០ ដល់ ២២ មករា អ្នកស្រាវជ្រាវជាន់ខ្ពស់ម្នាក់ បានចូលរួមក្នុងសិក្ខាសាលាលើ របៀបរចនារៀបចំត្រៀមជាមុនឆ្នាំ២០២០ (2020 Speculative Design Seminar) ដែលធ្វើឡើងនៅ សាកលវិទ្យាល័យ Sunway ប្រទេសម៉ាឡេស៊ី។

មជ្ឈមណ្ឌលនេះ ក៏បានរៀបចំការជួបប្រជុំមួយ ជាមួយ អគ្គនាយកដ្ឋាន អប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅថ្ងៃទី៥ មីនា ២០២០ ដែរ។

## មជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន

ក្រុមស្រាវជ្រាវបានបន្តសកម្មភាពក្នុងគម្រោងជាច្រើន រួមទាំងគម្រោងបីផ្ដល់មូលនិធិដោយ Sida ស្ដីពី ១) ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ, ២) ការបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើយេនឌ័រ ក្នុងសហគមន៍នៅតាមមូលដ្ឋាននៅកម្ពុជា (ការចុះសិក្សាដល់កន្លែងជាដំបូងបានអនុវត្តនៅដើមខែមីនា បន្តដោយការបង្កើតបញ្ជីសំណួរស្របតាមលទ្ធផលរកឃើញ), និង ៣) ការវាយតម្លៃសេវាប្រព័ន្ធអេកូឡូស៊ីក្នុងអេកូទេសចរណ៍ ផ្អែកលើសហគមន៍ដើម្បីថែរក្សាព្រៃឈើ និងកែលំអជីវភាពរស់នៅ។ ក្រុមស្រាវជ្រាវក៏បានចូលរួមក្នុងការអនុវត្តគម្រោងផ្ដល់មូលនិធិដោយ UNDP ស្ដីពី ផលប៉ះពាល់នៃកម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ហើយនិងគម្រោងទទួលបានមូលនិធិពី សហប្រតិបត្តិការមេគង្គឡានឆាង ស្ដីពី ការទូតលើធនធានទឹកនៅអាងទន្លេមេគង្គ ដើម្បីឈានទៅដល់ការប្រើប្រាស់អាងរួមគ្នាប្រកបដោយភាពរីកចម្រើន ដែលគ្រោងចប់រួចរាល់នៅខែឧសភា ២០២១។ នៅខែកុម្ភៈ ផ្នែកបរិស្ថានបានអនុវត្តចប់សព្វគ្រប់ នូវគម្រោងទទួលបានមូលនិធិពីសហប្រតិបត្តិការមេគង្គឡានឆាង ដែរ ស្ដីពី ការធ្វើកសិកម្មតាមកិច្ចសន្យាក្នុងតំបន់មេគង្គឡានឆាង។

ក្នុងត្រីមាសនេះដែរ ផ្នែកនេះបានរៀបចំកិច្ចសន្ទនាផ្នែកគោលនយោបាយមួយ ស្ដីពី ការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា៖ របៀបអនុវត្តល្អៗ បទពិសោធន៍រៀនសូត្របាន បញ្ហាចោទ និង

បញ្ហាប្រឈម។

អ្នកស្រាវជ្រាវម្នាក់ក្នុងផ្នែកនេះ បានចូលរួមក្នុង កម្មវិធីបណ្ដុះបណ្ដាលអន្តរជាតិ ស្ដីពី ការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ ដែលរៀបចំឡើងដោយ MSB-Sida (MSB: ទីភ្នាក់ងារស៊ុយអែតគ្រប់គ្រងព្រឹត្តិការណ៍ឥតព្រាងទុក) នៅក្រុង Kathmandu ប្រទេសនេប៉ាល់ ដើម្បីចែករំលែកចំណេះដឹងពីការចូលរួមឃ្លាំមើល វាយតម្លៃ និងជួយសម្របសម្រួលការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ។

**មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា**

នៅត្រីមាសទី១ ឆ្នាំ២០២០ ផ្នែកនេះបានចូលរួមក្នុងការអនុវត្តគម្រោងបួនសំខាន់ៗ ក្នុងនេះមានគម្រោងពីរកំពុងដំណើរការបន្តពីឆ្នាំ២០១៩ ដោយប្រើមូលនិធិរបស់ Sida ពោលគឺ គម្រោងស្ដីពី *ផលប៉ះពាល់នៃការប្រែប្រួលពីមួយជំនាន់ទៅមួយជំនាន់ទៅលើទំនាក់ទំនងរដ្ឋ-សង្គម នៅថ្នាក់ក្រោមជាតិ* ហើយនិង *ការចូលរួមបំពេញសកម្មភាពជាពលរដ្ឋរបស់យុវជន ជាមួយអង្គការសង្គមស៊ីវិល*។ ក្រោយបានចុះស្រាវជ្រាវដល់កន្លែងក្នុងខេត្តមួយចំនួន ក្រុមស្រាវជ្រាវកំពុងសរសេររបាយការណ៍ដែលគ្រោងចេញផ្សាយនៅខែមិថុនា។ គម្រោងថ្មីពីរទៀតបានចាប់ផ្ដើមនៅដើមឆ្នាំនេះ។ ទី១ គឺ គម្រោង ស្ដីពី *ភាពជាម្ចាស់នៅកម្រិតជាតិ និងការចូលរួមនៅកម្រិតមូលដ្ឋាន* ដោយរួមសហការជាមួយសាកលវិទ្យាល័យ Gotenburg (ផ្ដល់មូលនិធិដោយ ក្រុមប្រឹក្សាស្រាវជ្រាវស៊ុយអែតៈ Swedish Research Council) ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលសិក្សាលើឯកសារ និងកំណត់អ្នកពាក់ព័ន្ធសំខាន់ៗ សម្រាប់ការចុះស្រាវជ្រាវដល់កន្លែង ចាប់ពីខែតុលា។ គម្រោងទី២ ស្ដីពី *ការពិនិត្យតាមទស្សនៈយេនឌ័រលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឥណទាន និងអាហារូបត្ថម្ភនៅតាមមូលដ្ឋាននៅកម្ពុជា និងនៅតំបន់អាស៊ីខាងត្បូង* ទទួលបានជំនួយគាំទ្រពី មូលនិធិស្រាវជ្រាវបញ្ហាប្រឈមសកល (GCRF) គឺកំពុងធ្វើការប្រមូលទិន្នន័យក្នុងបីភូមិនៅជនបទកម្ពុជា និងជាគម្រោងអនុវត្តរួមគ្នាជាមួយ Royal Holloway, University of London ព្រមទាំងក្រុមបច្ចេកទេសកម្ពុជា និងឥណ្ឌា ដើម្បីសិក្សា និងដាក់បញ្ចូលនូវ ការស្រាវជ្រាវឆ្លងវិស័យអំពី អាកាសធាតុ យេនឌ័រ និងអាហារូបត្ថម្ភ។

# សេចក្ដីប្រកាសទទួលអត្ថបទ

## ឆ្នាំទី២៤ លេខ២ (ខែមិថុនា ឆ្នាំ២០២០)

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ជាឯកសារឈានមុខដែល វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ធ្វើការបោះពុម្ពផ្សាយប្រចាំត្រីមាសជាភាសា ខ្មែរ និង អង់គ្លេស។ ទស្សនាវដ្ដីនេះផ្ដល់នូវ វេទិកាមួយសម្រាប់ការពិភាក្សា និងការផ្ដល់សារៈសំខាន់ដល់បញ្ហាអភិវឌ្ឍន៍នៅកម្ពុជា។ ក្នុងផ្នែក តាមដានសេដ្ឋកិច្ច ទស្សនាវដ្ដីនេះធ្វើការពិនិត្យបូកសរុបពីលទ្ធផលម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា ហើយ "ទំព័រអ្នកស្រាវជ្រាវវ័យក្មេង" សំដៅជួយបង្កើនវត្តមានរបស់អ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រជំនាន់ក្រោយ ដើម្បីសម្រួលឲ្យមានការពិចារណារៀបចំគោលនយោបាយសេដ្ឋកិច្ចសង្គមកិច្ចតាមទស្សនៈរបស់អ្នកមានវ័យក្មេង។ ទស្សនាវដ្ដីមួយលេខៗ តាមធម្មតាមានចុះផ្សាយអត្ថបទចំនួនបី ដែលរៀបចំឡើងដោយអ្នកស្រាវជ្រាវនៅ CDRI និងនៅមជ្ឈដ្ឋានខាងក្រៅ ដោយផ្អែកលើប្រធានបទកំណត់ដោយ គណៈកម្មការនិពន្ធ ឬ ថ្នាក់ដឹកនាំ CDRI។ អត្ថបទនីមួយៗមានប្រវែងមិនលើសពី ២.៥០០ពាក្យ ក្នុងនោះមានទាំង តារាង និង/ឬ រូបភាព មិនលើសពី ៥ និងឯកសារយោង មិនលើសពី ១០។ មជ្ឈដ្ឋានអ្នកអាន រួមមាន អ្នកអនុវត្តការងារផ្នែកជំនួយនិងអភិវឌ្ឍន៍ មន្ត្រីរដ្ឋាភិបាល បុគ្គលិកស្ថានទូត អ្នកស្រាវជ្រាវ និងសាធារណជន។

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ស្វាគមន៍សំណើចុះផ្សាយអត្ថបទផ្សេងៗ។ លិខិតបញ្ជូនអត្ថបទត្រូវមានចុះហត្ថលេខា និងអាសយដ្ឋានសម្រាប់ការទាក់ទងតបវិញ និងលេខទូរស័ព្ទ។ អ្នកនិពន្ធអត្ថបទគួរទាក់ទងមក CDRI សិន មុននឹងផ្ញើអត្ថបទមក ប៉ុន្តែអត្ថបទគ្មានការទាក់ទងជាមុន ក៏ CDRI យកមកពិនិត្យពិចារណាដែរ។ អត្ថបទទាំងអស់នឹងមានការកែសម្រួលភាសា។ CDRI រក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយគ្មានបញ្ជាក់ហេតុផល។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

កិច្ចសន្ទនាផ្នែកគោលនយោបាយ ស្តីពី **ការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា៖ របៀបអនុវត្តល្អៗ ការរៀនសូត្រ ចំណោទផុសឡើង និងបញ្ហាប្រឈម** នៅថ្ងៃទី៧ កុម្ភៈ នៅក្រុងភ្នំពេញ បានអញ្ជើញអ្នកពាក់ព័ន្ធមកជួបជុំគ្នាដើម្បីពិភាក្សាពី លទ្ធផលរកឃើញជាដំបូងៗ ចំណោទផុសឡើង បញ្ហាប្រឈម និងដំណោះស្រាយអាចប្រើបាន ក្នុងការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា។ អ្នកចូលរួមប្រមាណ ៣០នាក់ រួមមាន អ្នកកសាងគោលនយោបាយ, អ្នកតំណាងមកពី វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល, អ្នកអនុវត្តជាក់ស្តែង (កសិករសហករណ៍កសិកម្ម), អ្នកស្រាវជ្រាវ, និង អ្នកសិក្សាអប់រំ។ ឆ្លងតាមកិច្ចសន្ទនានេះ ក្រុមស្រាវជ្រាវអាចទទួលបានរូបភាពច្បាស់លាស់នៃការធ្វើកសិកម្មតាមកិច្ចសន្យានៅកម្ពុជា ក៏ដូចជាមតិយោបល់មួយចំនួនសម្រាប់ជួយកែលំអ គម្រោងការធ្វើកសិកម្មតាមកិច្ចសន្យានានា។

សន្និសីទផ្នែកគោលនយោបាយ ស្តីពី **សិក្ខាសាលាលើរបៀបរចនារៀបចំត្រៀមជាមុនឆ្នាំ២០២០** (2020 Speculative Design Seminar) ធ្វើឡើងនៅ សាកលវិទ្យាល័យ Sunway ប្រទេសម៉ាឡេស៊ី មានគោលដៅ ចែករំលែករបៀបរចនារៀបចំត្រៀមជាមុនក្នុងលក្ខណៈជាឧបករណ៍ សម្រាប់ការកសាងគោលនយោបាយ និងការស្រាវជ្រាវ ក៏ដូចជា បង្កើតទំនាក់ទំនង និងការផ្លាស់ប្តូរគ្នានូវគំនិតថ្មីៗ ក្នុងចំណោម មន្ត្រីស្ថាប័នរដ្ឋាភិបាល អ្នកតំណាងមកពីអាស៊ាននិងប្រទេសនេប៉ាល់ ដែលជាប់ពាក់ព័ន្ធនឹងការកសាងគោលនយោបាយ និងការស្រាវជ្រាវ។

កិច្ចប្រជុំរួមសហការគ្នាជាមួយ **អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ** នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី៥ មីនា រួមមាន មន្ត្រីរដ្ឋាភិបាល ៧នាក់ និងអ្នកស្រាវជ្រាវនៅផ្នែកអប់រំ នៃវិទ្យាស្ថាន CDRI។ កិច្ចប្រជុំមានគោលដៅ ពង្រឹងសហប្រតិបត្តិការក្នុងសកម្មភាពស្រាវជ្រាវ និងកសាងសមត្ថភាព និងបញ្ជាក់ទទួលស្គាល់ការចូលរួមចំណែកជាវិជ្ជមាន ក្នុងផ្នែកការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET)។

## ការស្រាវជ្រាវ

### មជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ

នៅត្រីមាសទី១ ឆ្នាំ២០២០ ផ្នែកនេះបានអនុវត្តគម្រោងស្រាវជ្រាវបួន។ គម្រោងផ្តល់មូលនិធិដោយ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ស្តីពី *ការអនុវត្តស្តង់ដាសុវត្ថិភាពក្នុងសាកវប្បកម្មនៅកម្ពុជា៖ ករណីដំណាំបន្លែ* បានចប់រួចរាល់ ហើយគម្រោងស្តីពី *ស្ថានភាពបច្ចុប្បន្ននៃឧស្សាហកម្មកែច្នៃកសិផល* បានចាប់ផ្តើមដំណាក់កាលដំបូងនៃការប្រមូលឯកសារ និងការកំណត់វិនិយោគមានសក្តានុពលនាពេលអនាគត រីឯគម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *ការវិភាគខ្សែសង្វាក់តម្លៃផ្លែស្វាយ* និងគម្រោងផ្តល់មូលនិធិដោយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ស្តីពី *បណ្តាញសម្រាប់ក្រុមផ្តល់គំនិតផ្នែកកសិកម្មនិងអភិវឌ្ឍន៍ជនបទសម្រាប់បណ្តាប្រទេសនៅមហាអនុតំបន់មេគង្គ (NARDT)* កំពុងដំណើរការទៅមុខ។

### មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍

ផ្នែកនេះ បានចូលរួមក្នុងគម្រោងផ្សេងៗជាច្រើន។ ក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការមេគង្គឡានឆាង ផ្នែកនេះបានទទួលហិរញ្ញវត្ថុសម្រាប់អនុវត្តគម្រោង ស្តីពី *ពាណិជ្ជកម្មផ្នែក*

*តទៅទំព័រ ២២*


ទស្សនាវដ្តី **អភិវឌ្ឍន៍កម្ពុជា**

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី២៤ លេខ១ ខែមីនា ឆ្នាំ២០២០

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ សម្រាប់ពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់នូវការវាយតម្លៃឯករាជ្យពីដំណើរការសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្តី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ +៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ 🖷 +៨៥៥២៣៨៨០៧៣៤

e-mail: cdri@cdri.org.kh

website: www.cdri.org.kh



9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសម្រួល: អ៊ុំ ចាន់ថា

កែសម្រួលផលិតកម្ម: ម៉េន ច័ន្ទធីតា

សហគ្រាសបោះពុម្ព Go Invent Media (GIM), រូបភាពទំព័រមុខ: រូបភាព វបសអ


© រក្សាសិទ្ធិ ២០១៩ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈវេបសាយ www.cdri.org.kh